**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឯកសារជំនួយស្មារតី
## របស់លោក អ៊ី សុខឡេង អភិបាល នៃគណៈអភិបាលក្រុងព្រះសីហនុ
## ថ្លែងក្នុងសន្និសីទសារព័ត៌មាន
## ស្តីពី
## "វឌ្ឍនភាព និងទិសដៅការងារបន្តរបស់រដ្ឋបាលក្រុងព្រះសីហនុ"

**ថ្ងៃព្រហស្បតិ៍ ១កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤**
**ទីស្តីការគណៈរដ្ឋមន្ត្រី, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២១**

**ជាដំបូងបំផុត**!...

- ខ្ញុំបាទសូមអរគុណ " **សន្តិភាព** " និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលជាអគ្គស្ថាបនិកសន្តិភាព " យើងប្តេជ្ញារួមគ្នាការពារសន្តិភាព "** *សូមអបអរសាទរ...!*

**ខ្ញុំបាទសូមគោរព!**

- **ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល **ជាទីគោរពដ៏ខ្ពង់ខ្ពស់!**
- **ឯកឧត្តម ជាម ហ៊ីម** ប្រធានក្រុមប្រឹក្សាខេត្ត និងជាប្រធានគណៈប្រតិភូខេត្តព្រះសីហនុ **ជាទីគោរពដ៏ខ្ពង់ខ្ពស់!**
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលមានវត្តមាននៅទីនេះ **ជាទីគោរពរាប់អាន!**

ថ្ងៃនេះក្នុងនាមរដ្ឋបាលក្រុងព្រះសីហនុ និងក្នុងនាមខ្លួនខ្ញុំបាទផ្ទាល់ ខ្ញុំពិតជាមានកិត្តិយស និងសប្បាយរីករាយ ដែលបានចូលរួមរាយការណ៍ពីវឌ្ឍនភាព និងទិសដៅបន្តរបស់រដ្ឋបាលក្រុងព្រះសីហនុ នៅក្នុងសន្និសីទសារព័ត៌មាន នាពេលនេះ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**ឯកឧត្តម ផៃ ស៊ីផាន** រដ្ឋមន្ត្រីប្រតិភូ អមនាយករដ្ឋមន្ត្រី និងជាប្រធានអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំអង្គសន្និសីទសារព័ត៌មាននេះ និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម ជាម ហ៊ីម** ប្រធានក្រុមប្រឹក្សាខេត្ត **ឯកឧត្តម គួច ចំរើន** អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ ដែលបានផ្តល់ឱកាសដល់ខ្ញុំបាទបានចូលរួមរាយការណ៍ពីវឌ្ឍនភាព និងទិសដៅបន្តរបស់រដ្ឋបាលក្រុងព្រះសីហនុ នាពេលនេះ។

**សូមគោរព ឯកឧត្តម លោកជំទាវ លោក-លោកស្រី ជាទីគោរព...!**

ខ្ញុំបាទសូមអនុញ្ញាតគោរពរាយការណ៍ពីវឌ្ឍនភាព និងទិសដៅបន្តរបស់រដ្ឋក្រុងព្រះសីហនុ ដោយសង្ខេប ដូចខាងក្រោម ៖

## I- ស្ថានភាពទូទៅក្រុងព្រះសីហនុ

### ១. ស្ថានភាពភូមិសាស្ត្រ

**ក្រុងព្រះសីហនុ** គឺជាក្រុងមួយក្នុងចំណោមក្រុង-ស្រុកទាំង៥របស់ខេត្តព្រះសីហនុ ដែលជាទីក្រុងកំពង់ផែ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងទេសចរណ៍ និងត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាតំបន់សេដ្ឋកិច្ចគំរូពហុបំណងស្រប តាមគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ និងជាទីក្រុងតំបន់ឆ្នេរ ស្ថិតនៅប៉ែកនិរតី នៃប្រទេសកម្ពុជា ដែលមានផ្ទៃដីទំហំសរុប ៨៤,៣៦៤ គីឡូម៉ែត្រការ៉េ ដែលមានព្រំប្រទល់ ៖

- ខាងកើតទល់នឹង : ស្រុកព្រៃនប់ និងស្រុកស្ទឹងហាវ
- ខាងលិចទល់នឹង : ក្រុងកោះរ៉ុង
- ខាងជើងទល់នឹង : ស្រុកស្ទឹងហាវ
- ខាងត្បូងទល់នឹង : ស្រុកព្រៃនប់

### ២. ប្រជាសាស្ត្រ

- ក្រុងព្រះសីហនុ មានប្រជាពលរដ្ឋរស់នៅអចិន្ត្រៃយ៍សរុបចំនួន **២៤.០៦៣គ្រួសារ** (ក្នុងនោះគ្រួសារ អចិន្ត្រៃយ៍ ១៧.៨៨៦គ្រួសារ គ្រួសារបណ្ដោះអាសន្ន ៦.១៧៧គ្រួសារ) ប្រជាពលរដ្ឋសរុបចំនួន **៨៣.៦១០នាក់** ក្នុងនោះស្ត្រីចំនួន ៤២.០៣៣ នាក់ ប្រជាពលរដ្ឋមានអាយុ ១៨ឆ្នាំឡើង ចំនួន **៥៣.១៨២នាក់** ។

- ក្នុងឆ្នាំ២០២០ ជនបរទេសដែលមកស្នាក់នៅរយៈពេលយូរនៅក្រុងព្រះសីហនុ មានចំនួន ៥៤សញ្ជាតិ សរុបចំនួន **១៦.៨៧៤នាក់** ស្រី ៣.៤៤២នាក់ ប្រៀបធៀបឆ្នាំ២០១៩ ថយចុះចំនួន ១៩.១០៥នាក់ ស្មើនឹង ៥៣% ក្នុងនោះជនជាតិចិនមានចំនួនសរុបច្រើនជាងគេគឺ ១២.០៨២នាក់ ស្រី ២.៣២២នាក់ ក្នុងនោះរួមមាន:

| | |
|---|---|
| ១. ជនជាតិចិន ១២.០៨២នាក់ (ស្រី ២.៣២២នាក់) | ១៥. នេប៉ាល់ ៣៣នាក់ (ស្រី ០២នាក់) |
| ២. ឥណ្ឌូនេស៊ី ១.៧២៧នាក់ (ស្រី៣៤២នាក់) | ១៦. អ៊ុយក្រែន ៣២នាក់ (២០នាក់) |
| ៣. ថៃ ៦៧៥នាក់ (ស្រី ៦៦នាក់) | ១៧. អូស្ត្រាលី ២៨នាក់ (០៨នាក់) |
| ៤. ម៉ាឡេស៊ី ៤១៨នាក់ (ស្រី ៩៨នាក់) | ១៨.ទួរគី ៣២នាក់ (ស្រី ០៧នាក់) |
| ៥. ភូមា ៤៩៧នាក់ (ស្រី ២២៣នាក់) | ១៩.ជប៉ុន ២៨នាក់ (០២នាក់) |
| ៦. វៀតណាម ២០១នាក់ (ស្រី ៥២នាក់) | ២០.អ៊ីតាលី ២៤នាក់ (០៥នាក់) |
| ៧. ហ្វីលីពីន ២៥៧នាក់ (ស្រី ៨៥នាក់) | ២១.យូប៊ីគីស្ថាន ១៤នាក់ (០០នាក់) |
| ៨. តៃវ៉ាន់ ១៥៦នាក់ (ស្រី ២៣នាក់) | ២២.កាណាដា ១៣នាក់ (ស្រី ៤នាក់) |
| ៩. រុស្ស៊ី ១៦៧នាក់ (ស្រី ៩៧នាក់) | ២៣.អាមេរិក ១៤នាក់ (ស្រី ៣នាក់) |
| ១០.កូរ៉េខាងត្បូង ១៧៣នាក់ (ស្រី ២៤នាក់) | ២៤.ស្វីស ៨នាក់ (ស្រី ១នាក់) |
| ១១.ឥណ្ឌា ៧៥នាក់ (ស្រី ០៤នាក់) | ២៥.ស្រីលង្កា ១នាក់ (ស្រី ០០នាក់) |
| ១២.បារាំង ៦៦នាក់ (ស្រី ១៥នាក់) | ២៦.អ៊ីស្រាអែល ៥នាក់ (ស្រី ១នាក់) |
| ១៣.អង់គ្លេស ៤០នាក់ (ស្រី ១១នាក់) | ២៧.ប៉ូឡូញ ០៧នាក់ (ស្រី ២នាក់) |
| ១៤.សឹង្ហបុរី ០៩នាក់ (ស្រី ០២នាក់) | ២៨.គៀហ្ស៊ីស៊ីស្ថាន ៣នាក់ (ស្រី ១នាក់) |

២៩.ហូឡង់ ០៥នាក់ (ស្រី ០១នាក់)
៣០.អេស្ប៉ាញ ០៦នាក់ (ស្រី ២នាក់)
៣១.អៀកឡង់ដ៏ ០២នាក់ (ស្រី ០០នាក់)
៣២លីតធូនៀ ០២នាក់ (ស្រី ០១នាក់)
៣៣.អាហ្វ្រិកខាងត្បូង ០៧នាក់ (ស្រី ៤នាក់)
៣៤.ស្កត់ឡែន ០៣នាក់ (ស្រី ១នាក់)
៣៥.អូទ្រីស ០៣នាក់ (ស្រី ១នាក់)
៣៦.ឡាវ ០២នាក់ (ស្រី ០០នាក់)
៣៧.ណ័រវែស ០៣នាក់ (ស្រី ០១នាក់)
៣៨.ដានណឺម៉ាក ០៣នាក់ (ស្រី ០១នាក់)
៣៩.ហ្សីមប៉ាវេ ០១នាក់ (ស្រី ០១នាក់)
៤០.មូរីតាន ០១នាក់ (ស្រី ០១នាក់)
៤១.ហ្សាប៊ី ០១នាក់ (ស្រី ០០នាក់)
៤២.អាល្លឺម៉ង ១៦នាក់ (ស្រី ០៥នាក់)
៤៣.បេឡារ៉ូស ០៥នាក់ (ស្រី នាក់)
៤៤.អាហ្វ្រិក-កើត ២នាក់ (ស្រី១នាក់)
៤៥.ព័រទុកហ្គាល់ ០២នាក់ (ស្រី០នាក់)
៤៦.កាហ្សាស្ថាន ០១នាក់ (ស្រី១នាក់)
៤៧.អាយស៍ឡែន ០៣នាក់ (ស្រី ០នាក់)
៤៨.ឆែក ០២នាក់ (ស្រី ១នាក់)
៤៩.អេស្តូនៀ ០៤នាក់ (ស្រី ២នាក់)
៥០.ហេឡេនិក ០១នាក់ (ស្រី ០នាក់)
៥១.រ៉ូម៉ានី ០១នាក់ (ស្រី ០នាក់)
៥២.នីហ្សេរីយ៉ា ០១នាក់ (ស្រី ០នាក់)
៥៣.កែនយ៉ា ០១នាក់ (ស្រី១នាក់)
៥៤.ប៉ាគីស្ថាន ០១នាក់ (ស្រី០នាក់)

### ៣. ការបែងចែករដ្ឋបាល

ក្រុងព្រះសីហនុ ចែកចេញជា ០៤សង្កាត់ និង ១៥ភូមិ រួមមាន៖

- សង្កាត់លេខ១ ចំនួន ៣ភូមិ
- សង្កាត់លេខ២ ចំនួន ៣ភូមិ
- សង្កាត់លេខ៣ ចំនួន ៣ភូមិ
- សង្កាត់លេខ៤ ចំនួន ៦ភូមិ

### ៤/. សក្តានុពលក្រុងព្រះសីហនុ

- ឆ្នេរសមុទ្រប្រវែង **២៤,៥ គីឡូម៉ែត្រ** ( ខេត្តព្រះសីហនុ មានឆ្នេរប្រវែង ១៧៥.៨គីឡូម៉ែត្រ )។
- កោះមានចំនួន ០៥ ( កោះព្រាប កោះដែកគោល កោះពស់ កោះថាស និងកោះត្រេះ ) និងមានថ្មដុះចំនួន ១ទីតាំង ( ថ្មដុះអាចម៍សត្វ ) ( ខេត្តព្រះសីហនុ មានកោះចំនួន ៣២ )។
- ធនធានសមុទ្រសម្បូរបែបជាច្រើនទៀតដូចជាៈ ត្រី ក្តាម បង្គារ មឹក ផ្កាថ្ម...។ល។
- កំពង់ផែស្វយ័តអន្តរជាតិក្រុងព្រះសីហនុ ជាកំពង់ផែសមុទ្រទឹកជ្រៅជាងគេបំផុតក្នុងប្រទេសកម្ពុជា
  - កំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេសក្នុងកំពង់ផែក្រុងព្រះសីហនុ មានផ្ទៃដីសរុប ១២៤,៦ ហិកតា។
  - មានចំណតផែសរុបប្រវែង ១.៨៦០ ម៉ែត្រ។
  - ចំណតនាវាសរុប ១២ចំណត
  - ទីលានមានសមត្ថភាពស្តុកកុងតឺន័របាន ២១.០០០ TEUs ( សមមូលកុងតឺន័រ ២០ហ្វីត )។
  - ជម្រៅទឹកដែលអនុញ្ញាតអោយនាវាចូលចត៖
    - នាវាដឹកកុងតឺន័រ ជម្រៅ ៨.៥០ ម៉ែត្រ
    - នាវាដឹកទំនិញរាយ ជម្រៅ ១០.៥០ ម៉ែត្រ ( សម្រាប់ចំណតផែពហុបំណង )
  - សមត្ថភាពទំនិញឆ្លងកាត់ប្រចាំឆ្នាំ
    - កុងតឺន័រឆ្លងកាត់ ៧៥០.០០០ TEUs/ឆ្នាំ ( សមមូលកុងតឺន័រ ២០ហ្វីត )
    - ទំនិញទូទៅឆ្លងកាត់ ៨.០០០.០០០ តោន/ឆ្នាំ
- ផ្លូវដែក-ផ្លូវរថភ្លើង មានប្រវែង ២៦៤គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មកក្រុងព្រះសីហនុ បច្ចុប្បន្នផ្លូវដែក បានបម្រើសេវាដឹកអ្នកដំណើរ និងដឹកជញ្ជូនប្រេង និងទំនិញបម្រើឱ្យវិស័យឧស្សាហកម្ម។

- **ផ្លូវគោក ៖**
    - ផ្លូវជាតិលេខ៤ មានចម្ងាយ ២៣០គីឡូម៉ែត្រ ទៅរាជធានីភ្នំពេញ ដែលអំណោយផលសម្រាប់ការដឹកជញ្ជូនទំនិញគ្រប់ប្រភេទពីមូលដ្ឋានក្រុង ទៅកាន់រាជធានីភ្នំពេញ និងតាមបណ្ដាខេត្តក្នុងប្រទេសកម្ពុជា និងជាបណ្ដាញផ្លូវគោកសម្រាប់បន្តទៅខេត្តផ្សេងៗទៀត
    - គម្រោងសាងសង់ផ្លូវល្បឿនលឿន (Express Way) ពីរាជធានីភ្នំពេញមកកាន់ក្រុងព្រះសីហនុ មានប្រវែងប្រមាណជាង ១៩០គីឡូម៉ែត្រ សម្រេចបានប្រមាណ ៣០% គិតត្រឹមខែមករា ឆ្នាំ២០២១។ គម្រោងសាងសង់ផ្លូវល្បឿនលឿននេះ បានបើកការដ្ឋាននៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២០ ដោយរយៈពេលសាងសង់ចំនួន ៤៨ខែ ហើយគ្រោងនឹងបញ្ចប់ការសាងសង់មុនពេលកំណត់នាចុងឆ្នាំ២០២២ ដោយគ្រោងប្រើប្រាស់ថវិកាវិនិយោគប្រមាណ ២.០០០ លានដុល្លារអាមេរិក។

## II- ការធានាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

គណៈបញ្ជាការឯកភាពក្រុងព្រះសីហនុ មានកម្លាំងប្រដាប់អាវុធទាំង **០៣ប្រភេទ** សរុបចំនួន**១៤៧នាក់ (ស្រី០៦នាក់)** រួមមាន ៖

- កងកម្លាំងអធិការដ្ឋាននគរបាលក្រុងមានចំនួន **៩៦នាក់** (ស្រី ០៦នាក់)
- កងរាជអាវុធហត្ថក្រុងចំនួន **៤៤នាក់**
- ផ្នែកសឹករងក្រុងចំនួន **០៧នាក់**
- កម្លាំងប្រជាការពារទូទាំងក្រុងសរុបចំនួន **៤៣៧ នាក់** ក្នុងនោះ៖ កម្លាំងប្រជាការពារក្រុង ចំនួន ២៩នាក់ សង្កាត់លេខ១ ចំនួន ១៨៨នាក់ សង្កាត់លេខ២ ចំនួន ១៣នាក់ សង្កាត់លេខ៣ ចំនួន ១៦២ នាក់ និងសង្កាត់លេខ៤ ចំនួន ៤៥នាក់។

ក្នុងនោះគណៈបញ្ជាការឯកភាពក្រុងព្រះសីហនុ បានប្រជុំជាទៀងរាល់ខែ ដើម្បីត្រួតពិនិត្យ និងដាក់ផែនការពង្រឹងសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គមឱ្យបានកាន់តែល្អប្រសើរ បម្រើដល់ការរស់នៅរបស់ប្រជាពលរដ្ឋ ភ្ញៀវទេសចរ និងអ្នកវិនិយោគនៅក្នុងក្រុងព្រះសីហនុ មានភាពកក់ក្ដៅ។

### ក/. សភាពការណ៍បទល្មើសផ្សេងៗ

ក្នុងឆ្នាំ២០២០ សភាពការណ៍បទល្មើសកើតឡើងចំនួន ២៩២ ករណី ក្នុងនោះ៖

- បទល្មើសឧក្រិដ្ឋមានចំនួន **២៤ករណី** ស្មើនឹង ៣២លើក ប្រៀបធៀបឆ្នាំ២០១៩ មាន ៣១ករណី ស្មើនឹង ៣១លើក គឺមានការថយចុះ ០៧ករណី និងកើន ០១លើក។
- បទល្មើសមជ្ឈិមមានចំនួន **១៣០ករណី** ស្មើនឹង ១៣៣លើក ប្រៀបធៀបឆ្នាំ២០១៩ មាន ១៦៦ លើក ស្មើនឹង ១៦៦លើក គឺថយចុះ ៣៦ករណី និងថយចុះ ៣៣លើក។
- ការជួញដូរមនុស្ស ចំនួន ០៩នាក់ ស្មើនឹង ១០លើក ក្នុងនោះជនរងគ្រោះចំនួន ៩នាក់ (ករណីនេះទើបកាត់ចេញពីបទល្មើសព្រហ្មទណ្ឌ ក្នុងឆ្នាំ២០២០)
- បទល្មើសគ្រឿងញៀន ចំនួន **៥៥ករណី** ស្មើនឹង ៥៣លើក ប្រៀបធៀបឆ្នាំ២០១៩ មាន ៤៨ករណី ស្មើនឹង ៤៩លើក គឺមានការកើនឡើង ៦ករណី និងកើន ០៤លើក។
- គ្រោះថ្នាក់ផ្សេងៗចំនួន **៨២ករណី** ស្មើនឹង ១៤០លើក ប្រៀបធៀបឆ្នាំ២០១៩ មាន ១០៤ករណី ស្មើនឹង ១០៤លើក គឺមានការថយចុះ ២២ករណី និងថយចុះ ៣៦លើក។

### ខ/. ការធ្វើរដ្ឋបាលចំហរ

គណៈបញ្ជាការឯកភាពក្រុងព្រះសីហនុ បានចុះធ្វើរដ្ឋបាលចំហរនៅក្នុងភូមិសាស្ត្រក្រុង បានចំនួន **៣៨លើក** ក្នុងនោះ៖

- នៅភូមិសាស្ត្រសង្កាត់លេខ១ មានចំនួន ១៩លើក
- នៅភូមិសាស្ត្រសង្កាត់លេខ២ មានចំនួន ០២លើក
- នៅភូមិសាស្ត្រសង្កាត់លេខ៣ មានចំនួន ០៥លើក
- នៅភូមិសាស្ត្រសង្កាត់លេខ៤ មានចំនួន ១២លើក

### គ/. ការចុះត្រួតពិនិត្យអាវុធជាតិផ្ទុះ

គណៈបញ្ជាការឯកភាពក្រុងព្រះសីហនុ បានដាក់កម្លាំងគណៈបញ្ជាការឯកភាព ចុះត្រួតពិនិត្យអាវុធជាតិផ្ទុះនៅតាមគោលដៅផ្លូវសំខាន់ៗ នៅក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ បានចំនួន ៣៤លើក។

### ឃ/.ការដាក់កម្លាំងប្រចាំការ ២៤ម៉ោង នៅតាមទីតាំងគោលដៅសំខាន់ៗ ៖

គណៈបញ្ជាការឯកភាពក្រុងព្រះសីហនុ បានប្រើប្រាស់កម្លាំងចំនួន **៤៦នាក់** ប្រចាំការ ២៤/២៤ម៉ោង នៅតាមគោលដៅសំខាន់ៗ ដូចជា គោលដៅដែលមានប្រជាពលរដ្ឋរស់នៅច្រើន កន្លែងរមណីយដ្ឋាន តាមតំបន់ឆ្នេរ ផ្សារ កន្លែងអាជីវកម្ម និងតាមបណ្តាផ្លូវដែលមានការធ្វើចរាចរច្រើន ដើម្បីពង្រឹងសន្តិសុខ បង្ការទប់ស្កាត់ការលួច-ឆក់ប្លន់ និងបង្ក្រាបបទល្មើសឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ដូចខាងក្រោម ៖

- សង្កាត់លេខ១ មាន ០៣គោលដៅ កម្លាំងប្រចាំការចំនួន ១០នាក់
- សង្កាត់លេខ២ មាន ០២គោលដៅ កម្លាំងប្រចាំការចំនួន ០៨នាក់
- សង្កាត់លេខ៣ មាន ០៣គោលដៅ កម្លាំងប្រចាំការចំនួន ១០នាក់
- សង្កាត់លេខ៤ មាន ០៣គោលដៅ កម្លាំងប្រចាំការចំនួន ១៨នាក់

**ង/. ការដាក់កម្លាំងចុះល្បាត៖** ប្រើប្រាស់កម្លាំងចំនួន ៣៦នាក់ ចុះធ្វើការល្បាតត្រួតពិនិត្យសភាពការណ៍រួមនៅក្នុងភូមិសាស្ត្រក្រុងចំនួន ៣វេន តាមពេលវេលាដូចខាងក្រោម៖

- វេនទី១ ល្បាតចាប់ពីម៉ោង ១១:០០នាទីថ្ងៃត្រង់ ដល់ម៉ោង ០១:០០នាទីរសៀល
- វេនទី២ ល្បាតចាប់ពីម៉ោង ០៥:០០នាទីល្ងាច ដល់ម៉ោង ០៨:០០នាទីយប់
- វេនទី៣ ល្បាតចាប់ពីម៉ោង ១២:០០នាទីយប់ ដល់ម៉ោង ០៤:០០នាទីព្រឹក

## III- ការងារផ្តល់សេវាសាធារណៈ

### ១. ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលក្រុងព្រះសីហនុ

ក្នុងឆ្នាំ២០២០នេះ ការិយាល័យច្រកចេញចូលតែមួយ នៃរដ្ឋបាលក្រុងព្រះសីហនុ បានផ្តល់សេវាសាធារណៈលើវិស័យទាំង១៤ ជូនដល់ប្រជាពលរដ្ឋសរុប **២៤.៧៣៤នាក់** ក្នុងនោះស្រី ៩.៦៤១នាក់ បានចំនួន **២៧.៦២៣សេវា** ស្មើនឹងទឹកប្រាក់ចំនួន **២៧៦.២៧៦.០០០រៀល** នៃគម្រោងផែនការឆ្នាំ២០២០ ចំនួន **៩០០.៤៣០.០០០រៀល** ទន្ទឹមនេះបើប្រៀបធៀបឆ្នាំ២០១៩ សេវាចំនួន ២៧.០៥៨សេវា ស្មើនឹងទឹកប្រាក់ចំនួន **៩៨៥.២១៥.០០០រៀល** ដោយសេវាមានកើនឡើងចំនួន ២% ស្មើនឹងទឹកប្រាក់គិតជាភាគរយថយចុះចំនួន ៧២%។ ចំពោះសេវាមានការកើនឡើង ចំណូលថយចុះ មូលហេតុដោយសារសេវានីត្យានុកូលកម្មកើនឡើងច្រើន ប៉ុន្តែសេវាផ្សេងៗទៀត មានការថយចុះច្រើនជាងមុន។

- សំណង់ ចំនួន៣៩២ ប្រជាពលរដ្ឋទទួលសេវា ១៩៦នាក់ ទឹកប្រាក់ ១៣៨.៨៣៤.០០០រៀល
- ពាណិជ្ជកម្ម ចំនួន៣៤២ ប្រជាពលរដ្ឋទទួលសេវា ៣០៨នាក់ ទឹកប្រាក់ ៨.៥២៥.០០០រៀល
- វប្បធម៌ ចំនួន២២៤ ប្រជាពលរដ្ឋទទួលសេវា ២០២នាក់ ទឹកប្រាក់ ១៣.០០០.០០០រៀល
- ទេសចរណ៍ ចំនួន៨៦ ប្រជាពលរដ្ឋទទួលសេវា ៧៧នាក់ ទឹកប្រាក់ ១២.១៧០.០០០រៀល
- ឧស្សាហកម្ម ចំនួន១៦ ប្រជាពលរដ្ឋទទួលសេវា ១៤នាក់ ទឹកប្រាក់ ៧០០.០០០រៀល
- សាធារណការ ចំនួន ១១៤៨ ប្រជាពលរដ្ឋទទួលសេវា១.០៣៣នាក់ ទឹកប្រាក់ ០០រៀល
- នីត្យានុកូលកម្ម ១៩.០៨៩ ប្រជាពលរដ្ឋទទួលសេវា១៧.១៨០នាក់ ទឹកប្រាក់ ១៤.៤១២.០០០រៀល
- កសិកម្ម ចំនួន ១៥ ប្រជាពលរដ្ឋទទួលសេវា ១៤នាក់ ទឹកប្រាក់ ៣៧៥.០០០រៀល
- អប់រំ ចំនួន ៩ ប្រជាពលរដ្ឋទទួលសេវា ៨នាក់ ទឹកប្រាក់ ១.៤០០.០០០រៀល
- អត្រានុកូលដ្ឋានចំនួន ៦.០៦២ ប្រជាពលរដ្ឋទទួលសេវា ៥.៤៥៦ ទឹកប្រាក់ ០០រៀល
- សុខាភិបាល ចំនួន ៦៨ ប្រជាពលរដ្ឋទទួលសេវា ៦១នាក់ ទឹកប្រាក់ ១៣.៤៦០.០០០រៀល
- សុរិយោដី ចំនួន ១៧២ ប្រជាពលរដ្ឋទទួលសេវា ១៥៥នាក់ ទឹកប្រាក់ ៧៣.៤០០.០០០រៀល
- រ៉ែ និងថាមពល (មិនទាន់មានសេវា)
- រដ្ឋបាល (មិនទាន់មានសេវា)

## ២. ការផ្តល់សេវាអត្រានុកូលដ្ឋានរបស់រដ្ឋបាលសង្កាត់ទាំង៤

ក្នុងឆ្នាំ២០២០នេះ រដ្ឋបាលសង្កាត់ទាំង៤ ក្នុងក្រុងព្រះសីហនុ បានផ្តល់សេវាអត្រានុកូលដ្ឋានជូនដល់ប្រជាពលរដ្ឋសរុបចំនួន **២.០៩២លិខិត** ក្នុងនោះសំបុត្រកំណើតសរុប **១.១៨៥លិខិត** (ស្រី ៥៩២នាក់) សំបុត្រអាពាហ៍ពិពាហ៍សរុប **៦៣៨លិខិត** និងសំបុត្រមរណភាពសរុប **២៦៩លិខិត** (ស្រី ១១២នាក់) រួមមាន៖

- រដ្ឋបាលសង្កាត់លេខ១ បានផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋបានចំនួន ៦៥៨លិខិត រួមមានសំបុត្រកំណើត ៤៥៨ លិខិត (ស្រី២១៤នាក់) សំបុត្រអាពាហ៍ពិពាហ៍ ១២២លិខិត និងសំបុត្រមរណភាព ៧៨លិខិត (ស្រី ៣៦នាក់)។
- រដ្ឋបាលសង្កាត់លេខ២ បានផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋបានចំនួន ២៤៦លិខិត រួមមានសំបុត្រកំណើត ១២៧លិខិត (ស្រី៥៨នាក់) សំបុត្រអាពាហ៍ពិពាហ៍ ៨៥គូ និងសំបុត្រមរណភាព ៣៤លិខិត (ស្រី១៧នាក់)។
- រដ្ឋបាលសង្កាត់លេខ៣ បានផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋបានចំនួន ៤១៤លិខិត រួមមានសំបុត្រកំណើត ២២៤ លិខិត (ស្រី១១៨នាក់) សំបុត្រអាពាហ៍ពិពាហ៍ ១៣២លិខិត និងសំបុត្រមរណភាព ៥៨ លិខិត (ស្រី ១៧)។
- រដ្ឋបាលសង្កាត់លេខ៤ បានផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋបានចំនួន ៧៧៤លិខិត រួមមានសំបុត្រកំណើត ៣៧៦លិខិត (ស្រី ២០២នាក់) សំបុត្រអាពាហ៍ពិពាហ៍ ២៩៩លិខិត និងសំបុត្រមរណភាព ៩៩លិខិត (ស្រី ៤២នាក់)។

## ៣. ការធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ

អធិការដ្ឋាននគរបាលក្រុងព្រះសីហនុ បានធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋក្នុងក្រុងព្រះសីហនុ ចាប់ពីដើមខែសីហា ឆ្នាំ២០២០ បានសរុបចំនួន **៣៩៣ នាក់** ដោយយោងទៅលើ៖

- លិខិតលេខ១៣៤ សជណ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការចាត់បញ្ជូនក្រុមការងារចល័តផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចំណុះអធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ទៅប្រចាំ

ការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដោយអនុវត្តតាមយន្តការដែលមានស្រាប់របស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។

- សេចក្តីជូនដំណឹងលេខ០២៩ សជណ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០ របស់រដ្ឋបាលក្រុងព្រះសីហនុ ស្តីពីការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋរស់ក្នុងក្រុងព្រះសីហនុ។

## IV. **ការងារអភិវឌ្ឍ**

### ១. គម្រោងរបស់គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា

**ក/. គម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវ ៣៤ខ្សែ៖** រាជរដ្ឋាបាលភិបាលកម្ពុជា តាមរយៈគណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា បានផ្តល់ថវិកាស្ថាបនាហេដ្ឋារចនាសម្ព័ន្ធផ្លូវនៅក្នុងភូមិសាស្ត្រក្រុងព្រះសីហនុចំនួន ៣១ខ្សែ ក្នុងចំណោមគម្រោងស្ថាបនាផ្លូវសរុបចំនួន ៣៤ខ្សែ ប្រវែងសរុប ៨២.៥០៥ម៉ែត្រ ក្នុងខេត្តព្រះសីហនុ ដែលបានសម្ពោធបើកការដ្ឋានដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលបានដំណើរការស្ថាបនាដោយក្រុមហ៊ុនចំនួន ៨ក្រុមហ៊ុន ទទួលគម្រោងស្ថាបនាផ្លូវទាំង ៣១ខ្សែ ក្នុងភូមិសាស្ត្រក្រុងព្រះសីហនុរួមមាន៖ វិថីលេខ៨៣៧-១ វិថីអូរត្រេះ ផ្លូវកាត់ទទឹងវិថីអូរត្រេះ និងឆ្នេរអូរត្រេះ វិថីអូរឈើទាល វិថីពូឡូវ៉ៃ វិថីឯករាជ្យ វិថី២ធ្នូ វិថីលំហែព្រះភូមិន្ទ វិថីឆ្នេរអូរត្រេះ វិថីបុរីកម្មករ វិថីជោតញ្ញាណ ផ្លូវលេខ៨០១ វិថី២៨មិថុនា ផ្លូវលេខ៥០១ ផ្លូវលេខ៥០៣ ផ្លូវលេខ៥០៥ ផ្លូវលេខ៥០៧ វិថីមិត្តភាពកម្ពុជា-រុស្ស៊ី វិថីចំណោតអូរត្រាវ ផ្លូវគុជអាស៊ី ផ្លូវលេខ១១៥ ផ្លូវលេខ៦០២ វិថីសន្តិភាព ផ្លូវលេខ៦០៨ ផ្លូវលេខ៥០២ ផ្លូវលេខ៨១០ ផ្លូវលេខ៨១៨ ផ្លូវលេខ១០២ ផ្លូវលេខ៨០៦ ផ្លូវលេខ១០៦ និងផ្លូវលេខ១២៦ ស្របទៅតាមប្លង់គោល និងការរចនាប្លង់របស់គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។ បច្ចុប្បន្នវឌ្ឍនភាពនៃការស្ថាបនាផ្លូវទាំង ៣១ខ្សែខាងលើ ក្នុងឆ្នាំ២០២០ មានដូចខាងក្រោម៖

- ការងារចាក់បេតុងផ្លូវសម្រេចបាន ១00%
- ការងារដាក់លូតាមផ្លូវសម្រេចបាន ១00%
- ការងាររៀបចំប្រព័ន្ធលូរណបសម្រេចបាន ១00%
- ការងាររៀបខឿនថ្មក្រានីតសម្រេចបាន ៩៣,៧៥%
- ការងាររៀបចំកម្រាលក្រានីតសម្រេចបាន ៩២,៤៣%
- ការងារតម្លើងបង្គោលភ្លើងតាមដងផ្លូវសម្រេចបាន ៩៩,០៥%
- ការងារបំពាក់អំពូលភ្លើងតាមដងផ្លូវសម្រេចបាន ៩១,២៥%
- ការងារដាំដើមឈើ សម្រេចបាន ៨៦,១៩%
- ការងារអ៊ុតបេទីម សម្រេចបាន ៣០,៦៦%
- ការងារគំនូសទេសចរណ៍ ស្តុបចរាចរណ៍ និងការងារបំពាក់កាមេរ៉ាសុវត្ថិភាព នឹងអនុវត្តបន្ត។

**ខ/. ការរៀបចំអាងចម្រោះទឹកកខ្វក់របស់គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា**

គណៈកម្មាធិការជាតិគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា បាននឹងកំពុងស្ថាបនាស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ចំនួន **២កន្លែង** និងស្ថានីយបូមទឹកកខ្វក់ចំនួន **៤កន្លែង** សរុបចំនួន ០៦កន្លែង ដូចខាងក្រោម ៖

១- **ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់**ចំនួន ២កន្លែង មានសមត្ថភាពធ្វើប្រព្រឹត្តិកម្មទឹកកខ្វក់សរុប **១២.៤០០ ម៉ែត្រគីប ក្នុង១ថ្ងៃ** រួមមានៈ ស្ថានីយ៍ទី១/. សាងសង់លើផ្ទៃដីទំហំ ៣២ម៉ែត្រ X ៨០ម៉ែត្រ វឌ្ឍនភាពបាន ៥៧% មានសមត្ថភាពចម្រោះបាន ៥.២០០ម៉ែត្រគីប ក្នុង១ថ្ងៃ និងស្ថានីយ៍ទី២/. សាងសង់លើផ្ទៃដីទំហំ ២៥ម៉ែត្រ x ១៨៥ម៉ែត្រ វឌ្ឍនភាពបាន៤៨% មានសមត្ថភាពចម្រោះបាន ៧.២០០ម៉ែត្រគីប ក្នុង១ថ្ងៃ។

២- **ស្ថានីយ៍បូមទឹកកខ្វក់** ចំនួន ០៤ទីតាំង និងបានបំពាក់ម៉ូទ័របូមផលិតនៅប្រទេសជប៉ុនម៉ាក EBARA មានមុខកាត់ ២៥០/ចេញ ៣០០មីលីម៉ែត្រ សរុបចំនួន ១០គ្រឿង ដើម្បីបូមបង្ហូរទឹកកខ្វក់កុំឱ្យហូរចូលទៅសមុទ្រ។

**គ/. ការរៀបចំសួនច្បារ**

- ការងារដាំផ្កាក្រដាសសួនកណ្ដាលមេដ្យានផ្លូវទាំង ៣មហាវិថី បានបញ្ចប់ ១០០%
  - មហាវិថីរាម ដាំផ្កាក្រដាសបានប្រមាណ ១០.០០០ដើម
  - មហាវិថីឆ្នេររាម ដាំផ្កាក្រដាសបានប្រមាណ ៩.៨០០ដើម
  - មហាវិថីជំទាវម៉ៅ ដាំផ្កាក្រដាសបានប្រមាណ ១.៨៣៥០ដើម
- ការងារសួនឆ្នេរអូរឈើទាលមានបរិមាណប្រមាណ ៣.៣៤០ម៉ែត្រការ៉េ សម្រេចបានប្រមាណ ៩៥% (នៅសល់ទីតាំងចុងឆ្នេរអូរឈើទាល កំពុងសាងសង់ជញ្ជាំងទប់ដី)។
- ការងារសួនឆ្នេរអូរត្រេះមានបរិមាណប្រមាណ ៥.៧០០ ម៉ែត្រការ៉េ សម្រេចបានប្រមាណ ៩៥% (នៅសល់ប្រមាណ ២៥០ ម៉ែត្រការ៉េ)។

**ឃ/. បន្ទប់ទឹកសាធារណៈ**

ការងារសាងសង់បន្ទប់ទឹកសាធារណៈទាំង ៩ទីតាំង តាមបណ្ដោយឆ្នេរសម្រេចបានប្រមាណ ៣០,៥% មានខាងក្រោម៖

*** ក្រុមហ៊ុន ពិស្ណុការ**

- បន្ទប់ទឹកទី០១ ៖ ការងារគ្រោង (Structure) សម្រេចបានប្រមាណ ៧៥%
- បន្ទប់ទឹកទី ០២ ៖ ការងារគ្រោង (Structure) សម្រេចបានប្រមាណ ៩៤%
- បន្ទប់ទឹកទី០៥ ៖ ការងារគ្រោង (Structure) សម្រេចបានប្រមាណ ៨១%

*** ក្រុមហ៊ុន ហេង សម្បត្តិ**

- បន្ទប់ទឹកទី០៧ ៖ ការងារគ្រោង (Structure) សម្រេចបានប្រមាណ ៥៦%
- បន្ទប់ទឹកទី០៩ ៖ ការងារគ្រោង (Structure) សម្រេចបានប្រមាណ ៥៦%
- បន្ទប់ទឹកទី១១ ៖ ការងារគ្រោង (Structure) សម្រេចបានប្រមាណ ៨១%

*** ក្រុមហ៊ុន វីធី៖**

- បន្ទប់ទឹកទី១២ (ការងារគ្រោង (Structure) សម្រេចបានប្រមាណ ១០០% រួចរាល់ ការងារស្ថាបត្យកម្ម សម្រេចបានប្រមាណ ១៧%)

*** កងវិស្វកម្មក្រសួងមហាផ្ទៃ**

- បន្ទប់ទឹកទី០៣ ៖ ការងារគ្រោង (Structure) សម្រេចបានប្រមាណ ៥០%
- បន្ទប់ទឹកទី០៦ ៖ ការងារគ្រោង (Structure) សម្រេចបានប្រមាណ ៤៨%

## ២. គម្រោងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន

ក្រៅពីគម្រោងស្ថាបនាហេដ្ឋារចនាសម្ព័ន្ធទាំង ៣៤ខ្សែ រាជរដ្ឋាភិបាល តាមរយៈក្រសួងសាធារណការ និងដឹកជញ្ជូន បានផ្ដល់កញ្ចប់ថវិកាសន្សំរបស់ជាតិចំនួន ១០០លានដុល្លារអាមេរិក ដើម្បីស្ថាបនាផ្លូវបន្ថែមចំនួន ១១ ខ្សែទៀត ដែលមានប្រវែង ៥៨.៧២១ម៉ែត្រ ( ជាង ៥៨គីឡូម៉ែត្រ ) ដែលបានសម្ពោធបើកការដ្ឋាននៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ក្រោមអធិបតីភាព**ឯកឧត្តម សួង ហេង** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន តំណាង**ឯកឧត្តម ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ជាលទ្ធផលសម្រេចបាន ២១,៣២ភាគរយ រួមមានឈ្មោះ និងប្រវែងដូចខាងក្រោម៖

១- ស្ពានផ្លូវលេខ ១៤៦បេ ប្រវែង ៤៣.០២៥ម៉ែត្រ វឌ្ឍនភាពជាភាគរយ ៦,៥៩%
២- ស្លាបនាផ្លូវជាតិលេខ៤ ប្រវែង ៦.៧០០ម៉ែត្រ វឌ្ឍនភាពជាភាគរយ ៥៤,៥១%
៣- ស្លាបនាផ្លូវក្រុងលេខ៨២៧ ប្រវែង ១.៣៥៧ម៉ែត្រ វឌ្ឍនភាពជាភាគរយ ១៨,៧៤%
៤- ស្លាបនាផ្លូវក្រុងលេខ៨២៣ ប្រវែង ១.៧២៥ម៉ែត្រ វឌ្ឍនភាពជាភាគរយ ៤៦,២៧%
៥- ស្លាបនាផ្លូវក្រុងលេខ៨១៤ ប្រវែង ១.៣០៥ម៉ែត្រ វឌ្ឍនភាពជាភាគរយ ៥៦,៩៣%
៦- ស្លាបនាផ្លូវក្រុងលេខ១០៣ ប្រវែង ១.១០០ម៉ែត្រ វឌ្ឍនភាពជាភាគរយ ៥៤,០៤%
៧- ស្លាបនាផ្លូវក្រុងលេខ១៤៣ ប្រវែង ៥០០ម៉ែត្រ វឌ្ឍនភាពជាភាគរយ ៤៨,៨២%
៨- ស្លាបនាផ្លូវក្រុងលេខ១០៨៣ ប្រវែង ២៤០ម៉ែត្រ វឌ្ឍនភាពជាភាគរយ ៤៥,១០%
៩- ស្លាបនាផ្លូវក្រុងលេខ២០៩ ប្រវែង ៣៤០ម៉ែត្រ វឌ្ឍនភាពជាភាគរយ ៤៦,៨០%
១០- ស្លាបនាផ្លូវក្រុងលេខ២០០ ប្រវែង ១.៥២០ម៉ែត្រ វឌ្ឍនភាពជាភាគរយ ៤១,១២%
១១- ស្លាបនាផ្លូវក្រុងលេខ១០៤ ប្រវែង ១.៣៥០ម៉ែត្រ វឌ្ឍនភាពជាភាគរយ ១៥,៩១%

## ៣. គម្រោងអភិវឌ្ឍរបស់រដ្ឋបាលខេត្តព្រះសីហនុ

សម្រាប់ឆ្នាំ២០២០ រដ្ឋបាលខេត្តព្រះសីហនុ មានគម្រោងចំនួន **១៤ គម្រោង** ដោយប្រើប្រាស់ថវិកាអស់ចំនួន ៤៦.១៥៨.៧០០.០០០ លានរៀល ក្នុងនោះមាន៖

- គម្រោងជួសជុលហេដ្ឋារចនាសម្ព័ន្ធក្នុងក្រុងព្រះសីហនុ (ផ្លូវ លូ ស្ពាន..) ចំនួន ៨គម្រោង ប្រើប្រាស់ថវិកាអស់ ៤០.៨៣៨.៥០០.០០០ រៀល មានដូចខាងក្រោម៖
  - ជួសជុលផ្លូវលេខ១០២១ ក្រាលបេតុងប្រវែង ១៨៣៤ម៉ែត្រ ទទឹង ៧ម៉ែត្រ កម្រាស់ ០.២៥ម៉ែត្រ អស់ថវិកា ៤.១០៩.១៤០.០០០រៀល
  - ជួសជុលលូទឹកភ្លៀងមុខកាត់ ០,៨ម៉ែត្រ លូទឹកស្អុយមុខកាត់ ០.៥ម៉ែត្រ លូសងខាងផ្លូវតាមបណ្ដោយផ្លូវលេខ១០២១ អស់ថវិកា ៥.៨៦៨.៨០០.០០០រៀល
  - ជួសជុលស្ពានចំនួន ២កន្លែង ទទឹង ៨ម៉ែត្រ បណ្ដោយ ១៥ម៉ែត្រ ថវិកា ១.៩២៦.០៦០.០០០រៀល
  - ជួសជុលផ្លូវលេខ១០៣៥ ក្រាលបេតុង និងលូប្រអប់ ១កន្លែង ទទឹង ៥ម៉ែត្រ បណ្ដោយ ១៦ម៉ែត្រ អស់ថវិកា ២.៦៩៩.២០០.០០០រៀល
  - ជួសជុលលូទឹកភ្លៀងមុខកាត់ ១ម៉ែត្រ លូទឹកស្អុយមុខកាត់ ០.៥ម៉ែត្រ សងខាងផ្លូវ១០៣៥ អស់ថវិកា ៤.៣៤៩.០០០.០០០រៀល
  - ជួសជុលផ្លូវលេខ២០០ ក្រាលបេតុង និងអ៊ុតកៅស៊ូAC កម្រាស់ ០.០០ម៉ែត្រ លូទឹកភ្លៀងមុខកាត់ ១ម៉ែត្រ និងលូទឹកស្អុយមុខកាត់ ០.៥ម៉ែត្រ អស់ថវិកា ១៦.៩២៥.០០០.០០០ម៉ែត្រ
  - ជួសជុលបណ្ដាញលូចាប់ពីផ្លូវលេខ១០៣ ទៅទួលខ្សាច់ មុខកាត់ ១ម៉ែត្រ អស់ថវិកា ៩២០.០០០.០០០រៀល។
  - ជួសជុលស្ពានបេតុង តាមបណ្ដោយផ្លូវលេខ៣០១ អស់ថវិកា៤.០៤១.៣០០.០០០រៀល។
- គម្រោងសាងសង់អាគារ (អគាររដ្ឋបាលក្រុងកោះរ៉ុង ច្រកចេញចូលតែមួយក្រុងកោះរ៉ុង មណ្ឌលសុខភាពក្រុងកោះរ៉ុង និងច្រកចេញចូលតែមួយស្រុកកំពង់សីលា) មានចំនួន ៣គម្រោង ប្រើប្រាស់ថវិកាអស់ចំនួន ៣.៩០០.០០០.០០០រៀល។
- គម្រោងជួសជុលក្លោងទ្វា និងរបង (សាលាខេត្តព្រះសីហនុ) ចំនួន ១គម្រោង ប្រើប្រាស់ថវិកាអស់ ៤៩៩.៥០០.០០០រៀល។

- គម្រោងជួលជុលបណ្តាញភ្លើងបំភ្លឺសាធារណៈ (តាមបណ្តោយផ្លូវលេខ៧០២ បានចំនួន ៦៤បង្គោល និងផ្លូវលេខ៨០០ បាន ២៨បង្គោល) ចំនួន ១ គម្រោង ប្រើប្រាស់ថវិកាអស់ ៦១៣.២០០.០០០ រៀល
- គម្រោងបង្ហោះដ្រូនពីលើអាកាស វាស់វែងប្រមូលទិន្នន័យ ព័ត៌មានភូមិសាស្ត្រ និងវិភាគទិន្នន័យជលសាស្ត្រ ក្នុងក្រុងព្រះសីហនុ ចំនួន ១គម្រោង ប្រើប្រាស់ថវិកាអស់ ៣០៧.៥០០.០០០ រៀល។

## ៨. គម្រោងអភិវឌ្ឍរបស់រដ្ឋបាលក្រុងព្រះសីហនុ

នៅក្នុងឆ្នាំ២០២០ រដ្ឋបាលក្រុងព្រះសីហនុ មានគម្រោងអភិវឌ្ឍចំនួន ៣គម្រោង និងមានទឹកប្រាក់សរុបចំនួន ២៦១.០០០.០០០រៀល គិតជាដុល្លារចំនួន ៦៥.២៥០ ដុល្លារអាមេរិក រួមមាន៖

- គម្រោងទី១ ទឹកប្រាក់ ១៦០.០០០.០០០រៀល សម្រាប់ចាក់សាបនៅក្នុងទីធ្លាសាលាក្រុង ទទួលស្ថាបនាគម្រោងដោយក្រុមហ៊ុន ហ៊្សរ ប៉ូ ខនស្រាក់សិន ចាប់ផ្តើមអនុវត្តគម្រោងនៅពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ និងបានបញ្ចប់គម្រោងជាស្ថាពរនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០។
- គម្រោងទី២ ទឹកប្រាក់ ៦២.០០០.០០០រៀល សម្រាប់ជួសជុលរបងសាលាក្រុង ទទួលស្ថាបនាគម្រោងដោយក្រុមហ៊ុន ហ៊្សរ ប៉ូ ខនស្រាក់សិន ចាប់ផ្តើមអនុវត្តគម្រោងនៅពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ និងបានបញ្ចប់គម្រោងនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០។
- គម្រោងទី៣ ទឹកប្រាក់ ៣៩.០០០.០០០រៀល សម្រាប់ជួសជុលអគារច្រកចេញចូលតែមួយ ការិ.សាធារណការ ដឹកជញ្ជូន អនាម័យ បរិស្ថាន និងសណ្តាប់ធ្នាប់សាធារណៈ និងអង្គភាពលទ្ធកម្ម ទទួលស្ថាបនាគម្រោងដោយក្រុមហ៊ុន ហ៊្សរ ប៉ូ ខនស្រាក់សិន ចាប់ផ្តើមអនុវត្តគម្រោងនៅពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ និងបានបញ្ចប់គម្រោងនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០។

## ៩. គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលសង្កាត់ទាំង៤ មានចំនួន

គម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលសង្កាត់ទាំង៤ ប្រចាំឆ្នាំ២០២០ មានផ្លូវចំនួន **០៧ខ្សែ** ប្រវែងសរុប **២.២៤៨ ម៉ែត្រ** ប្រើប្រាស់ថវិកា **១.៣៦២.៩៥៨.៩៣៣ រៀល** មានដូចខាងក្រោម៖

* សង្កាត់លេខ១ មានចំនួន ០១គម្រោង ស្ថាបនាផ្លូវបេតុងចំនួន ០២ខ្សែ ប្រវែងសរុប ៥២៧ម៉ែត្រ មានទឹកប្រាក់ ៣១៥.១៥១.១៩១រៀល គិតជាដុល្លារចំនួន ៧៩.១០៣ដុល្លារអាមេរិក ទទួលគម្រោងស្ថាបនាដោយក្រុមហ៊ុន សុខ មានជ័យ បើកការដ្ឋានកាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ រួមមានៈ

- គម្រោងទី១ ស្ថាបនាផ្លូវបេតុង ចំនួន ០១ខ្សែ នៅភូមិ៣(ទំនប់រលក) សង្កាត់លេខ១ មានទទឹង ៥ ម៉ែត្រ និងប្រវែង ៣០ម៉ែត្រ (កំពុងស្ថាបនា)។
- គម្រោងទី២ ស្ថាបនាផ្លូវបេតុង ចំនួន ០១ខ្សែ នៅភូមិ១ សង្កាត់លេខ១ មានទទឹង ៦ម៉ែត្រ និងប្រវែង ៤៩៧ម៉ែត្រ (កំពុងស្ថាបនា)។

* សង្កាត់លេខ២ មានគម្រោងអភិវឌ្ឍចំនួន ០១គម្រោង សម្រាប់ស្ថាបនាផ្លូវបេតុង ចំនួន ០២ខ្សែ ប្រើប្រាស់ថវិកាសរុបចំនួន ២៧០.០០០.០០០រៀល ស្មើនឹង ៦៧.៥០០ដុល្លារអាមេរិក ទទួលការស្ថាបនាដោយក្រុមហ៊ុន ហ៊្សរ ប៉ូ ខនស្រាក់សិន និងបានបើកការដ្ឋានកាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០រួមមានៈ

- គម្រោងទី១ ចំណាយទឹកប្រាក់ចំនួន ១៧០.០០០.០០០រៀល ស្ថាបនាផ្លូវបេតុងអាមេ មានទទឹង ៦ម៉ែត្រ ប្រវែង ២៥០ម៉ែត្រ និងកម្រាស់0.១៥ម៉ែត្រ ស្ថិតនៅក្រុមទី១៣ ភូមិ៣ (កំពុងស្ថាបនា)។
- គម្រោងទី២ ចំណាយទឹកប្រាក់ចំនួន ១០០.០០០.០០០រៀល ស្ថាបនាផ្លូវបេតុងអាមេ មានទទឹង ៤ ម៉ែត្រ ប្រវែង ១៥០ម៉ែត្រ និងកម្រាស់0.១៥ម៉ែត្រ ស្ថិតនៅក្រុមទី១០ ទី១៣ ភូមិ៣ (កំពុងស្ថាបនា)។

* សង្កាត់លេខ៣ មានគម្រោងអភិវឌ្ឍចំនួន ០១គម្រោង សម្រាប់ស្ថាបនាផ្លូវបេតុង ១ខ្សែ មានទទឹង ៦ម៉ែត្រ ប្រវែង ៥២០ម៉ែត្រ កម្រាស់ ០.២ម៉ែត្រ ប្រើប្រាស់ថវិកា ៣០៦.៩៦៧.៧៤២រៀល ទទួលការស្ថាបនាដោយក្រុមហ៊ុន ជា គីមសាន ខនស្រាក់សិន-អែនជីនារីង ដែលបានបើកការដ្ឋានកាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ គ្រោងបញ្ចប់នៅចុងខែមករា ឆ្នាំ២០២០ ។

* សង្កាត់លេខ៤ មានគម្រោងអភិវឌ្ឍចំនួន ២គម្រោង សម្រាប់ស្ថាបនាផ្លូវបេតុងអាមេរចំនួន ២ខ្សែ ប្រវែងសរុប ៨០១ម៉ែត្រ ប្រើប្រាស់ថវិកាសរុបចំនួន ៤៧០.៨៤០.០០០រៀល គិតជាដុល្លារចំនួន ១១៧.៧១០ដុល្លារអាមេរិក ដែលទទួលអនុវត្តដោយក្រុមហ៊ុន យ៉ិន សុខ និងបានបើកការដ្ឋានកាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ រួមមានៈ

- គម្រោងទី១ ចំណាយទឹកប្រាក់ចំនួន ១១៣.៨៨០.០០០រៀល ស្ថាបនាផ្លូវបេតុងអាមេ មានទទឹង ៥ម៉ែត្រ ប្រវែង ៤៥០ម៉ែត្រ និងកម្រាស់០.២ម៉ែត្រ ស្ថិតនៅភូមិ១ សង្កាត់លេខ៤ (កំពុងស្ថាបនា)។
- គម្រោងទី២ ចំណាយទឹកប្រាក់ចំនួន ៣៣៦.៩៦០.០០០រៀល ស្ថាបនាផ្លូវបេតុងអាមេ មានទទឹង ៦ម៉ែត្រ ប្រវែង ៣៥១ម៉ែត្រ និងកម្រាស់០.២ម៉ែត្រ ស្ថិតនៅភូមិ១ សង្កាត់លេខ៤ (កំពុងស្ថាបនា)។

* **សូមបញ្ជាក់ជូន** ចំពោះការស្ថាបនាផ្លូវទាំង ៨៧ខ្សែ ខាងលើ គឺផ្អែកទៅលើប្លង់ជាលក្ខណៈប្រព័ន្ធជាគោល ដូច្នេះរាល់សំណង់ដែលធ្វើរំលោភលើដីចិញ្ចើមផ្លូវ និងដីផ្លូវសាធារណៈ ម្ចាស់ត្រូវសហការជាមួយអាជ្ញាធរ មន្ទីរជំនាញ និងក្រុមហ៊ុនស្ថាបនាផ្លូវក្នុងការរុះរើសំណង់នោះចេញ ដើម្បីពន្លឿន និងសម្រួលដល់ការស្ថាបនាផ្លូវឱ្យបានរលូន និងសម្រេចតាមគម្រោងផែនការដែលបានគ្រោងទុក និងពុំមានដោះស្រាយគោលនយោបាយនោះទេ។

## V. ការបើកផ្លូវតាមប្លង់ជាលក្ខណៈប្រព័ន្ធ

ដើម្បីរួមចំណែកលើការងារអភិវឌ្ឍមូលដ្ឋាន និងដើម្បីសម្រួលដល់ការធ្វើចរាចរទៅមករបស់បងប្អូនប្រជាពលរដ្ឋឲ្យបានល្អប្រសើរជាងមុន ក្នុងឆ្នាំ២០២០នេះ រដ្ឋបាលក្រុងព្រះសីហនុ បានចេញសេចក្ដីជូនដំណឹងស្ដីពីការបើកផ្លូវតាមប្លង់ជាលក្ខណៈប្រព័ន្ធក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ និងបានចុះធ្វើការបើកផ្លូវរួចរាល់ជាស្ថាពរបានចំនួន **២៩ខ្សែ** មានប្រវែងសរុប **៨.១២៧ ម៉ែត្រ** ដូចខាងក្រោម៖

១- ផ្លូវលេខ១១៥ មានទទឹងចាប់ពី២០ម៉ែត្រ ទៅ៣០ម៉ែត្រ និងបណ្ដោយ ១.៤៥០ម៉ែត្រ ស្ថិតនៅភូមិ៣ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

២- ផ្លូវលេខ១០៣៣ មានទទឹងចាប់ពី១០ម៉ែត្រ ទៅ២០ម៉ែត្រ និងបណ្ដោយ ២៥០ម៉ែត្រ ស្ថិតនៅក្រុមទី៣ ក្រុមទី៤ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៣- ផ្លូវលេខ២០៩២ មានទទឹង ៦ម៉ែត្រ បណ្ដោយ ១៥០ម៉ែត្រ ស្ថិតនៅក្រុមទី១២ ភូមិ១ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៤- ផ្លូវតភ្ជាប់ពីផ្លូវលេខ៨១២ ទៅផ្លូវលេខ៨១៤ មានទទឹង ៥ម៉ែត្រ បណ្ដោយ ៣៥០ម៉ែត្រ ស្ថិតនៅក្រុមទី៣៩ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៥- ផ្លូវតភ្ជាប់ពីផ្លូវលេខ១០២ មកមុំផ្លូវអតីតអិលវី មានទទឹង ៥ម៉ែត្រ បណ្ដោយ ៦៤ម៉ែត្រ ស្ថិតនៅក្រុមទី៣ ភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៦- ផ្លូវតភ្ជាប់ពីផ្សារលើទៅផ្លូវលេខ១០៣ មានទទឹង ៥ម៉ែត្រ បណ្ដោយ ៣០០ម៉ែត្រ ស្ថិតនៅក្រុមទី៣ ភូមិ២ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៧- ផ្លូវលេខ៨០៦៤ ពីផ្សារលើទៅផ្លូវលេខ៨០៦ មានទទឹងចាប់ពី ៥ម៉ែត្រ ទៅ៦.៦ម៉ែត្រ បណ្តោយ ៤៥០ម៉ែត្រ ស្ថិតនៅភូមិ១ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៨- ផ្លូវតភ្ជាប់ពីផ្លូវលេខ១០៣៣ ទៅផ្លូវលេខ១០៣៥ មុំទួលខ្សាច់ មានទទឹង ៥ម៉ែត្រ ទៅ ១២.៥ម៉ែត្រ បណ្តោយ ២៤០ម៉ែត្រ ស្ថិតនៅក្រុមទី២ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

៩- ផ្លូវតភ្ជាប់ពីផ្លូវលេខ៨១៨ ដល់សាលាដុនបូស្កូ (អូរ៥) មានទទឹងចាប់ពី ៩.៥ម៉ែត្រ ទៅ១៣.៥ម៉ែត្រ បណ្តោយ ៣៥០ម៉ែត្រ ស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

១០- ផ្លូវលេខ៨១៨.៥ មានទទឹង៨ម៉ែត្រ ទៅ ៩ម៉ែត្រ បណ្តោយ ១៩០ម៉ែត្រ ស្ថិតនៅក្រុមទី១៨ ភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

១១- ផ្លូវតភ្ជាប់ពីផ្លូវលេខ១១២.៦ ទៅផ្លូវលេខ១១២.៨ ពីសាលាឡាយហ្វ ទៅផ្លូវសេតេ មានទទឹង ៥ម៉ែត្រ បណ្តោយ ២០០ម៉ែត្រ ស្ថិតនៅក្រុមទី៤ ភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

១២- ផ្លូវពីសាលាឡាយហ្វទៅផ្លូវលេខ១១២ មានទទឹង ៤ម៉ែត្រ បណ្តោយ ២២០ម៉ែត្រ ស្ថិតនៅក្រុមទី២ និង ក្រុមទី៤ ភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

១៣- ផ្លូវតភ្ជាប់ពីផ្លូវ១០២ ទល់ផ្លូវអ៊ីលវី មានទទឹង ៥ម៉ែត្រ បណ្តោយ ១២៥ម៉ែត្រ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

១៤- ផ្លូវតភ្ជាប់ពីផ្លូវលេខ៨១៨ ទល់នឹងផ្លូវលេខ៨២០ មានទទឹង ៦ម៉ែត្រ បណ្តោយ ២៨០ម៉ែត្រ ស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

១៥- ផ្លូវខាងក្រោយសាលាដុនបូស្កូ មានទទឹង ៥ម៉ែត្រ បណ្តោយ ២៥០ម៉ែត្រ ស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

១៦- ផ្លូវតភ្ជាប់ពីផ្លូវលេខ២០០ មុំក្រោយតោពីរ មានទទឹង៥ម៉ែត្រ បណ្តោយ ៥៧០ម៉ែត្រ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

១៧- ផ្លូវមុំម្លប់តាប៉ាង មានទទឹង ៥ម៉ែត្រ និងបណ្តោយ ១២០ម៉ែត្រ ស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

១៨- ផ្លូវលេខ៨១៩ មានទទឹង ៥ម៉ែត្រ និងបណ្តោយ ៥០០ម៉ែត្រ ស្ថិតនៅភូមិ៥ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

១៩- ផ្លូវតភ្ជាប់លេខ៨០០ មានទទឹង ៥ម៉ែត្រ និងបណ្តោយ ៤០០ម៉ែត្រ ស្ថិតនៅភូមិ១ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

២០- ផ្លូវមុំទួលខ្សាច់ មានទទឹង ៥ម៉ែត្រ និងបណ្តោយ ១៦១ម៉ែត្រ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

២១- ផ្លូវលេខ១០២២ មានទទឹង ៥ម៉ែត្រ បណ្តោយ ២៥០ម៉ែត្រ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

២២- ផ្លូវបំបែកពីផ្លូវ១០២២ ទៅផ្លូវ១០២ មានទទឹង ៥ម៉ែត្រ និងបណ្តោយ ១៦០ម៉ែត្រ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

២៣- ផ្លូវបំបែកពីផ្លូវបេអេសអូរ១ មានទទឹង ៥ម៉ែត្រ និងបណ្តោយ ១០០ម៉ែត្រ ស្ថិតនៅភូមិ១ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

២៤- ផ្លូវតភ្ជាប់ពីផ្លូវ១០៣៧ មានទទឹង ៥ម៉ែត្រ និងបណ្តោយ ២៥០ម៉ែត្រ ស្ថិតនៅភូមិ៣ សង្កាត់លេខ៤ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

២៥- ផ្លូវលេខ១០២០ មានទទឹង ៥ម៉ែត្រ និងបណ្តោយ ២០៥ម៉ែត្រ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ (ម្លប់តាប៉ាងខាងក្រោយ)។

២៦- ផ្លូវលេខ១០២០ មានទទឹង ៥ម៉ែត្រ និងបណ្តោយ ១០០ម៉ែត្រ ស្ថិតនៅភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ (ម្លប់តាប៉ាងខាងមុខ)។

២៧- ផ្លូវ១០៣.៣ មានទទឹង ១០ម៉ែត្រ និងបណ្តោយ ២០០ម៉ែត្រ ស្ថិតភូមិ៤ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

២៨- ផ្លូវលេខ១១២ (សេតេ) មានទទឹង ៥ម៉ែត្រ និងបណ្តោយ ១១២ម៉ែត្រ ស្ថិតនៅភូមិ២ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

២៩- ផ្លូវលេខ ១១២២ មានទទឹង ៨ម៉ែត្រ និងបណ្តោយ ១៣០ម៉ែត្រ ស្ថិតនៅភូមិ២ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ (ផ្លូវក្បែរមន្ទីរព័ត៌មានខេត្តព្រះសីហនុ)។

## VI- **ការរៀបចំសណ្តាប់ធ្នាប់សាធារណៈ**

### ១. ការរៀបចំសណ្តាប់ធ្នាប់តាមផ្លូវសាធារណៈ:

**ក/.ការងារផ្សព្វផ្សាយ-អប់រំ**

រដ្ឋបាលក្រុង បានប្រជុំផ្សព្វផ្សាយវិធានការដល់ប្រជាពលរដ្ឋដែលប្រកបអាជីវកម្មតាមរទេះរុញ ម៉ូតូកង់បី និងឡានកែច្នៃ លក់ដូរសម្ភារប្រើប្រាស់ និងម្ហូបអាហារ បន្លែ ត្រី សាច់ តាមទីសាធារណៈក្នុងភូមិសាស្រ្តក្រុងព្រះសីហនុ មានចំនួន ៦វិធានការ ដូចខាងក្រោម៖

- ប្រជាពលរដ្ឋដែលប្រកបអាជីវកម្មតាមរទេះរុញ តាមម៉ូតូកង់បី និងឡានច្នៃ បានយល់ព្រមរកផ្ទះជួល ដើម្បីជួលស្នាក់នៅឲ្យបានច្បាស់លាស់ ( សូមបញ្ជាក់ជូនកន្លងមកពួកគាត់ បានស្នាក់នៅលើម៉ូតូកង់បី លើឡានច្នៃសង់រោងស្នាក់នៅលើដីចិញ្ចើមផ្លូវ ដីអូរ ដីសួរច្បារ និងដីឡូតិ៍គេ បណ្តាលឲ្យបាត់បង់សណ្តាប់ធ្នាប់)។
- ពួកគាត់បានយល់ព្រមឈប់ស្នាក់នៅលើម៉ូតូកង់បី លើឡានច្នៃ និងយល់ព្រមរុះរើរោងស្នាក់នៅតាមចិញ្ចើមផ្លូវ លើអូរ ដីសួនច្បារ និងដីឡូតិ៍គេ។
- ពួកគាត់បានយល់ព្រមឈប់ចតអចិន្ត្រៃយ៍ រទេះរុញ ម៉ូតូកង់បី និងឡានច្នៃ នៅលើដងផ្លូវ និងចិញ្ចើមផ្លូវ និងលើឆ្នេរខ្សាច់ ដើម្បីលក់ដូរសម្ភារៈប្រើប្រាស់ និងម្ហូបអាហារ បន្លែ ត្រី សាច់ ទៀតហើយ។
- បណ្តាផ្លូវសំខាន់ៗ និងផ្លូវធំៗ ដូចជាផ្លូវឯករាជ្យ ផ្លូវអូរឈើទាល ផ្លូវលំហែកាយព្រះភូមិន្ទ ផ្លូវប៉ូឡូវ៉េ ផ្លូវ ២ធ្នូ ផ្លូវ ២៨មិថុនា ដែលមានភ្ញៀវទេសចរណ៍ អ្នកវិនិយោគ និងប្រជាពលរដ្ឋ ធ្វើចរាចរច្រើន គឺមិនអនុញ្ញាតឲ្យម៉ូតូកង់បី និងឡានច្នៃ បើកលក់ដូរ តាមបណ្តាផ្លូវខាងលើនេះទេ ប៉ុន្តែបើបើកឆ្លងកាត់បាន។
- ប្រជាពលរដ្ឋដែលប្រកបអាជីវកម្មលក់ដូរសម្ភារប្រើប្រាស់ ម្ហូបអាហារ បន្លែ ត្រី សាច់ តាមរទេះរុញ តាមម៉ូតូកង់បី និងឡានច្នៃ តាមការដ្ឋានសំណង់ គឺមិនអនុញ្ញាតឲ្យឈប់ ឬ ចតអចិន្ត្រៃយ៍នៅលើដងផ្លូវ និងចិញ្ចើមផ្លូវមុខការដ្ឋានសំណង់នោះទេ។ រីឯតាមបណ្តោយឆ្នេរ ក៏មិនអនុញ្ញាតឲ្យឈប់ ឬ ចត លក់ដូរសម្ភារប្រើប្រាស់ និងម្ហូបអាហារ បន្លែ ត្រី សាច់ លើផ្ទៃឆ្នេរខ្សាច់ដែរ គឺត្រូវឈប់ និងចតបណ្តោះអាសន្ននៅខាងកើតផ្លូវតាមបណ្តោយឆ្នេរឲ្យមានរបៀបរៀបរយ ហើយពេលឈប់លក់ ត្រូវរុញរទេះ ជិះម៉ូតូបី បើកឡានច្នៃ និងប្រមូលសម្ភារៈ ទៅផ្ទះវិញ។
- ប្រជាពលរដ្ឋអ្នកលក់ដូរ សន្យាថែរក្សាបរិស្ថានដោយវេចខ្ចប់ និងទុកដាក់សំរាម ឲ្យបានត្រឹមត្រូវព្រមទាំងភ្ជាប់សេវាជាមួយក្រុមហ៊ុនសំរាម៕

**សូមបញ្ជាក់ជូនថា៖** ការលក់ដូរចល័ត ដោយប្រើប្រាស់មធ្យោបាយម៉ូតូ រឺម៉កកងបី រទេះ ឡានកែច្នៃ...ដាក់លក់សម្ភារប្រើប្រាស់ និងម្ហូបអាហារ បន្លែ ត្រីសាច់...។ល។ បានបង្កការលំបាកដូចខាងក្រោម៖

- បង្កឱ្យស្ទះចរាចរ និងអាចគ្រោះថ្នាក់ជាយថាហេតុ
- គ្មានសណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម
- បាត់បង់សោភ័ណភាពទីក្រុង
- លក់ដូរមិនបានវេចខ្ចប់ឱ្យបានត្រឹមត្រូវបង្កផលប៉ះពាល់បរិស្ថាន
- អ្នកលក់ដូរចល័តទាំងនោះ ភាគច្រើនមិនមានទីលំនៅច្បាស់លាស់ ដោយបានយកមធ្យោបាយទាំងនោះធ្វើជាកន្លែងស្នាក់នៅ និងចម្អិនម្ហូបអាហារ ព្រមទាំងយកចិញ្ចើមផ្លូវ ដីអូរ សួនច្បារ និងដីឡូតិ៍ម្ចាស់មិននៅសាងសង់កន្លែងស្នាក់នៅ និងលក់ដូរ។

## ខ. វិធានការរដ្ឋបាល

ក្នុងឆ្នាំ២០២០ រដ្ឋបាលក្រុងព្រះសីហនុ បានចុះរៀបចំសណ្តាប់បានចំនួន **៥៦៨ លើក** នៅតាមទីតាំងសំខាន់ៗដូចជាៈ ផ្លូវឯករាជ្យ ផ្លូវអូរឈើទាល ផ្លូវលំហែរព្រះភូមិន្ទ ផ្លូវពូលូវ៉ៃ ផ្លូវមុខរោងចក្រញ៉ូស្តារ ផ្លូវមុខផ្សារឃ្លាំងលើ ផ្សារពាណិជ្ជកម្ម ផ្សារទំនប់រលក ផ្សារលើ ផ្លូវកន្ទុយនាគ ផ្លូវ៥០២ ផ្លូវមុខវេទិកា៧មករា ផ្លូវមិត្តភាព ផ្លូវ២៨មិថុនា ផ្លូវ២ធ្នូ ផ្លូវ៧មករា ផ្លូវមិត្តភាព និងតាមបណ្តោយផ្លូវផ្សេងទៀតទូទាំងភូមិសាស្ត្រព្រះសីហនុ មានដូចខាងក្រោម ៖

- ស្ទូចឡានដែលចតលើការ៉ូឡាចិញ្ចើមផ្លូវ និងលើផ្លូវគ្មានសណ្តាប់ធ្នាប់បានចំនួន **៣៥៩គ្រឿង**
- ចាប់ម៉ូតូចតលើការ៉ូឡាចិញ្ចើមផ្លូវ និងលើផ្លូវគ្មានសណ្តាប់ធ្នាប់បានចំនួន **២៦១គ្រឿង**
- ចាប់រឺម៉កកង់បីចតលើការ៉ូឡាចិញ្ចើមផ្លូវ និងលើផ្លូវគ្មានសណ្តាប់ធ្នាប់បានចំនួន **៧៩គ្រឿង**
- និងចាប់សម្ភារផ្សេងៗ ចំនួន ១.២៩០ ( តុ ទូ កៅអី ធុងទឹកកក ឆ័ត្រ រទេះរុញ...។ល។ ) យកមករក្សាទុកនៅសាលាក្រុង ដើម្បីអប់រំ។

## គ. វិធានការច្បាប់

- រដ្ឋបាលក្រុង បានស្ទូចយានយន្តមករក្សាទុកនៅសាលាក្រុង និងធ្វើការផាកពិន័យទៅតាមច្បាប់ពាក់ព័ន្ធនឹងការរៀបចំសណ្តាប់ធ្នាប់សាធារណៈ។
- រដ្ឋបាលក្រុង មិនទាន់បានកសាងសំណុំរឿងពាក់ព័ន្ធនឹងករណីរៀបចំសណ្តាប់ធ្នាប់ បញ្ជូនទៅតុលាការដើម្បីអនុវត្តទៅតាមនីតិវិធីច្បាប់នៅឡើយទេ។

# ២. ការចុះរុះរើសំណង់អនាធិបតេយ្យនៅលើដីចំណីផ្លូវសាធារណៈ

ក្នុងឆ្នាំ២០២០នេះ រដ្ឋបាលក្រុង បានចុះរៀបចំសណ្តាប់ធ្នាប់ និងបានរុះរើសំណង់អនាធិបតេយ្យនៅលើដីចំណីផ្លូវសាធារណៈបានចំនួន **៣៤ផ្ទះ** ដែលមានទីតាំងខាងក្រោម ៖

- **ទីតាំងទី១** ស្ថិតនៅផ្លូវលេខ១១៥ ក្រុមទី៥ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ( ជាប់របងអតីតមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ ) ប្រជាពលរដ្ឋចំនួន ១៦គ្រួសារ ដែលមានផ្ទះ និងរស់នៅលើដីផ្លូវសាធារណៈ។
- **ទីតាំងទី២** ស្ថិតនៅផ្លូវលេខ១០៣៣ ក្រុមទី៣ និងក្រុមទី៤ ភូមិ៣ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រជាពលរដ្ឋចំនួន ៧គ្រួសារ ដែលមានផ្ទះ និងរស់នៅលើដីផ្លូវសាធារណៈ។

- **ទីតាំងទី៣** ស្ថិតនៅលើចិញ្ចើមផ្លូវជាតិលេខ៤ ( ទល់មុខអនុស្ថានីយ៍អគ្គិសនីក្រុង ) មុំឃ្លាំងលើ ក្រុមទី៩ ភូមិ២ សង្កាត់លេខ១ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ប្រជាពលរដ្ឋចំនួន ១១គ្រួសារ ដែលមានផ្ទះ និងរស់នៅលើដីផ្លូវសាធារណៈ។

## ៣. ការចុះរុះរើសំណង់អនាធិបតេយ្យគ្រប់ប្រភេទនៅតាមបណ្តោយឆ្នេរ

### ក/. វិធានការអប់រំ-ផ្សព្វផ្សាយ

ក្រុមការងាររដ្ឋបាលខេត្ត រដ្ឋបាលក្រុងព្រះសីហនុ មន្ទីរ-អង្គភាពពាក់ព័ន្ធ បានធ្វើការចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋដែលលក់ដូរអនាធិបតេយ្យនៅតាមបណ្តោយឆ្នេរអូរឈើទាល-២ អូរត្រេះ១-២ និងឆ្នេរលំហែកាយ នៅក្នុងភូមិសាស្រ្តក្រុងព្រះសីហនុ ដើម្បីរុះរើសំណង់អនាធិបតេយ្យចេញពីឆ្នេរ និងរៀបចំសោភ័ណភាពឆ្នេរឱ្យបានស្អាតឡើងវិញ មានដូចខាងក្រោម៖

- សេចក្តីជូនដំណឹងលេខ ៤៧៣ សជណ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តព្រះសីហនុ។
- សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តព្រះសីហនុ ។

### ខ/. វិធានការរដ្ឋបាល

ចាប់ពីថ្ងៃទី០៨ ខែមករា ដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ រដ្ឋបាលខេត្ត និងរដ្ឋបាលក្រុងព្រះសីហនុ ដោយមានការចូលរួមពីមន្ទីរពាក់ព័ន្ធ ចុះរុះរើសំណង់អនាធិបតេយ្យគ្រប់ប្រភេទនៅតាមបណ្តោយឆ្នេរ បានចំនួន **៣ ទីតាំង** ដោយមានកម្លាំងចូលរួមសរុប **៨៧២នាក់** ប្រើគ្រឿងចក្រចំនួន **១០៤គ្រឿង** រុះរើសំណង់អនាធិបតេយ្យចំនួន **២៩៤ទីតាំង** និងប្រើប្រាស់គ្រឿងចក្រប្រមូល និងដឹកជញ្ជូនសំណល់សំណង់ចេញពីឆ្នេរសរុប **១.៣៣២ ជើង** ស្មើនឹង **១០.៦៥៦តោន** សរុបលទ្ធផលទទួលបានជោគជ័យ១០០% ដូចខាងក្រោម៖

- **ទីតាំងទី១ ការរុះរើសំណង់អនាធិបតេយ្យគ្រប់ប្រភេទនៅឆ្នេរអូរឈើទាល២ (អតីតឆ្នេរអារីស្តុន)** នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ **លោក អ៊ី សុខឡេង** អភិបាលក្រុងព្រះសីហនុ បានដឹកនាំកម្លាំងចម្រុះសរុបចំនួន ៣៥១នាក់ និងប្រើប្រាស់គ្រឿងចក្រចំនួន ៤៣គ្រឿង សហការជាមួយមន្ទីរពាក់ព័ន្ធ ចុះរុះរើសំណង់អនាធិបតេយ្យគ្រប់ប្រភេទនៅតាមបណ្តោយឆ្នេរអូរឈើទាល-២ សរុបចំនួន ១២៦ទីតាំង និងប្រើគ្រឿងចក្រប្រមូល និងដឹកជញ្ជូនកាកសំណល់ចេញពីឆ្នេរ បានចំនួន ២៥៤ជើង ស្មើនឹង ២.០៣២តោន ទទួលបានជោគជ័យ ១០០% ។
- **ទីតាំងទី២ ការរុះរើសំណង់អនាធិបតេយ្យគ្រប់ប្រភេទនៅឆ្នេរអូរត្រេះ១-២** នៅថ្ងៃទី១៥ ខែមករា ឆ្នាំ ២០២០ **លោក អ៊ី សុខឡេង** អភិបាលក្រុងព្រះសីហនុ បានដឹកនាំកម្លាំងចម្រុះសរុបចំនួន ៤០៥នាក់ និងប្រើប្រាស់គ្រឿងចក្រចំនួន ៤៩គ្រឿង សហការជាមួយមន្ទីរពាក់ព័ន្ធ ចុះរុះរើសំណង់អនាធិបតេយ្យគ្រប់ប្រភេទនៅតាមបណ្តោយឆ្នេរអូរត្រេះ១-២ សរុបចំនួន ១៥៦ទីតាំង (អូរត្រេះ-១ ចំនួន ១០៨ទីតាំង និងអូរត្រេះ-២ ចំនួន ៤៨ទីតាំង) និងប្រើគ្រឿងចក្រប្រមូល និងដឹកជញ្ជូនកាកសំណល់ចេញពីឆ្នេរ បានចំនួន ១.០១០ជើង ស្មើនឹង ៨.០៨០តោន ទទួលជោគជ័យ ១០០% ។
- **ទីតាំងទី៣ ការរុះរើសំណង់អនាធិបតេយ្យគ្រប់ប្រភេទនៅឆ្នេរលំហែកាយ** នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ ២០២០ **លោក អ៊ី សុខឡេង** អភិបាលក្រុងព្រះសីហនុ បានដឹកនាំកម្លាំងចម្រុះសរុបចំនួន ១១៦នាក់ និងប្រើប្រាស់គ្រឿងចក្រចំនួន ១២គ្រឿង សហការជាមួយមន្ទីរពាក់ព័ន្ធ ចុះរុះរើសំណង់អនាធិបតេយ្យគ្រប់ប្រភេទនៅតាមបណ្តោយឆ្នេរលំហែកាយ សរុបចំនួន ១២ទីតាំងនិងប្រើគ្រឿងចក្រប្រមូល និងដឹកជញ្ជូនកាកសំណល់ចេញពីឆ្នេរ បាន ៦៨ជើង ស្មើនឹង ៥៤៤តោន ទទួលបានជោគជ័យ ១០០%។

## ៨. គម្រោងស្ពារ/កាយអូរ-ប្រឡាយ ក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ

រាជរដ្ឋាភិបាល តាមរយៈក្រសួងសាធារណការ និងដឹកជញ្ជូន ក៏បានផ្តល់ថវិកាស្ពារអូរ-ប្រឡាយ ចំនួន ១០ខ្សែ ( អូរ១, អូរ២, អូរ៣, អូរ៤, អូរ៥ និងអូរឈើទាល អូរសំអាត អូរអណ្តូងអ៊ុនតាក់ អូរអេម៉ារីអូរ អូរស្ពានឆេះ ) និងមានប្រវែងសរុប **២៥.៩៦៧ម៉ែត្រ** ស្ថិតនៅក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ ដែលបាន សម្ពោធបើកការដ្ឋានប្រព្រឹត្តទៅក្រោមអធិបតីភាព**ឯកឧត្តម ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូន** កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩។

**ក/. ការចុះចុះចុះបរកនិយាមការអូរ-ប្រឡាយ និងបាញ់ថ្នាំតាមប្លង់ជាលក្ខណៈប្រព័ន្ធ**

រដ្ឋបាលក្រុងព្រះសីហនុ បានចាត់តាំងក្រុមការងារដើម្បីសហការជាមួយក្រុមការងារអគ្គនាយកដ្ឋាន ចម្រោះទឹកកខ្វក់ នៃក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រុមការងារគ្រប់គ្រងប្រព័ន្ធលូ អូរ ប្រឡាយ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ខេត្ត ដែលមានសមាសភាព រដ្ឋបាលខេត្តព្រះសីហនុ មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តព្រះសីហនុ មន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះសីហនុ មន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ មន្ទីរបរិស្ថានខេត្តព្រះសីហនុ និងរដ្ឋបាលក្រុងព្រះសីហនុ បានសហការគ្នាចុះចុះចុះបរកនិយាមការអូរ-ប្រឡាយតាមប្លង់ប្រព័ន្ធ និងបានធ្វើអត្តសញ្ញាណម្ចាស់សំណង់ គ្រប់ប្រភេទនៅលើអូរ-ប្រឡាយ និងកំណត់អត្តសញ្ញាណប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដល់គម្រោង ស្ពារអូរ-ប្រឡាយ ស្ថិតក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ។

**ខ/. ការចុះស្រង់អត្តសញ្ញាណប្រជាពលរដ្ឋ** ដែលរងផលប៉ះពាល់ពីគម្រោងស្ពារអូរប្រឡាយក្នុងភូមិសាស្ត្រ ក្រុងព្រះសីហនុ ចំនួន **៧៣៤គ្រួសារ** ដូចខាងក្រោម ៖

- ប៉ះពាល់ទាំងស្រុងចំនួន ២២៤គ្រួសារ។
- ប៉ះពាល់សំណង់ដោយផ្នែកចំនួន ៥១០គ្រួសារ។

**គ/. ការរុះរើសំណង់លើអូរ-ប្រឡាយ សរុបចំនួន ៦១១ គ្រួសារ ដូចខាងក្រោម៖**

- រុះរើទាំងស្រុង ១៨១គ្រួសារ ។
- រុះរើដោយផ្នែកចំនួន ៤៣០គ្រួសារ ។

**ឃ/. សំណង់មិនទាន់រុះរើសរុបចំនួន ១២៣គ្រួសារ ដូចខាងក្រោម៖**

- សំណង់ប៉ះពាល់ទាំងស្រុងមិនទាន់រុះរើ ចំនួន ៤៣គ្រួសារ ។
- សំណង់ប៉ះពាល់ដោយផ្នែកមិនទាន់រុះរើ ចំនួន ៨០គ្រួសារ ។

**ង/. លទ្ធផលនៃការកាយ -ស្ពារ អូរប្រឡាយ** បានប្រវែង ២២.១៨៧ ម៉ែត្រ នៃប្រវែងសរុប ២៥.៩៦៧ ម៉ែត្រ រីឯនៅសល់ប្រវែង ៣.៧៨០ម៉ែត្រ នៅផ្នែកខាងលើផ្លូវលេខ៨០០ ( ផ្លូវមិត្តភាព ) ក្រសួងសាធារណការ និងដឹកជញ្ជូន នឹងកាយបន្តនៅពេលខាងមុខ ។

**ច/. ការផ្តល់ដីឡូត៍សម្បទានសង្គមពីរដ្ឋបាលខេត្តព្រះសីហនុ**

- សេចក្តីជូនដំណឹងលេខ០០៧ សជណ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២០ របស់រដ្ឋបាលក្រុង ព្រះសីហនុ ស្តីពីការបិទផ្សាយលើកទី១ ឈ្មោះប្រជាពលរដ្ឋចំនួន ១៨០គ្រួសារ ដែលមានសំណង់ គ្រប់ប្រភេទ ដែលរងផលប៉ះពាល់ទាំងស្រុងពីគម្រោងស្ពារអូរ-ប្រឡាយ ស្ថិតនៅក្នុងភូមិសាស្ត្រក្រុង ព្រះសីហនុ ខេត្តព្រះសីហនុ។

- សេចក្តីជូនដំណឹងលេខ០២១ សជណ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២០ ស្តីពីការផ្តល់ដីឡូតិ៍សម្បទានសង្គមកិច្ចវគ្គទី១ ដល់ប្រជាពលរដ្ឋរស់នៅ និងអាស្រ័យផលលើអូរ-ប្រឡាយចំនួន ១៨១ គ្រួសារ ដែលមានសំណង់គ្រប់ប្រភេទរងផលប៉ះពាល់ទាំងស្រុងពីគម្រោងស្តារអូរ-ប្រឡាយ នៅក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ ខេត្តព្រះសីហនុ។

**ឆ/. ពិធីចាប់ឆ្នោតទទួលដីសម្បទានសង្គមពីរដ្ឋបាលខេត្តព្រះសីហនុ**

នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ រដ្ឋបាលក្រុងព្រះសីហនុ បានរៀបចំពិធីចាប់ឆ្នោតយកលេខដីឡូតិ៍សម្បទានសង្គមកិច្ចវគ្គទី១ ផ្តល់ជូនដល់ប្រជាពលរដ្ឋចំនួន ១៨១គ្រួសារ ដែលរងផលប៉ះពាល់ពីគម្រោងស្តារអូរ-ប្រឡាយ ក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព**លោក ម៉ាង ស៊ីណេត** អភិបាលរងខេត្ត តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ។

- ប្រជាពលរដ្ឋទាំង ១៨១គ្រួសារ អញ្ជើញមកចំនួន ១៧១គ្រួសារ (អវត្តមាន ១០គ្រួសារ) បានចាប់ឆ្នោតយកលេខដីឡូតិ៍សម្រាប់ ១ឡូតិ៍ តាមពេលវេលាកំណត់ រីឯ ១០គ្រួសារដែលអវត្តមាន បានទៅចាប់ឆ្នោតនៅពេលក្រោយ នៅសាលាខេត្តព្រះសីហនុ។ បច្ចុប្បន្នគ្រួសារទាំង ១៨១គ្រួសារ បានទទួលដីសម្បទានសង្គមកិច្ចពីរដ្ឋបាលខេត្ត បានគ្រប់គ្រួសាររួចហើយ។
- ក្នុង១គ្រួសារ ទទួលបានដីឡូតិ៍ មានទទឹង ៤.៥ម៉ែត្រ គុណបណ្តោយ ២០ម៉ែត្រ ស្ថិតនៅភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

## VII- ការងាររៀបចំដែនដី នគររូបនីយកម្ម និងសំណង់

**១. ចរន្តការការងារចុះបញ្ជី**

- ការចុះបញ្ជីបំពេញបន្ថែម សរុបចំនួន **១៣៣ ប្លង់**

**២. ចរន្តការការងារចុះបញ្ជីបន្ត** សរុបចំនួន **៣.៨៣១ ប្លង់**

| | |
|---|---|
| - ផ្ទេរប័ណ្ណចំនួន | ១.១៩០ ប្លង់ |
| - ផ្ទេរដោយបំបែក | ៨៣៣ ប្លង់ |
| - ធ្វើអំណោយ | ០៩៩ ប្លង់ |
| - ធ្វើអំណោយដោយបំបែក | ០៤៣ ប្លង់ |
| - បំបែកទៅម្ចាស់ដើម | ៤៨៧ ប្លង់ |
| - បំបែកតាមសាលក្រម | ០១០ ប្លង់ |
| - សុំប្តូរ រូបភាពប្រើប្រាស់ | ០៤០ ប្លង់ |
| - សុំបង្រួមក្បាលដី | ០៦៥ ប្លង់ |
| - ផ្ទេរតាមដីកាសម្រេច | ០០២ ប្លង់ |
| - សុំកែតម្រូវទំហំដី | ០០៣ ប្លង់ |
| - សុំបំបែកតាមកិច្ចព្រមព្រៀង | ០០៦ ប្លង់ |
| - សុំធ្វើសន្និកម្ម | ០០៤ ប្លង់ |
| - សុំធ្វើប័ណ្ណទុតិយតា | ០១៤ ប្លង់ |
| - ចុះបញ្ជីចំណែកឯកជន | ១០៣៥ យូនីត |

**៣. ការងារវាស់វែងដី ផ្ទេរកម្មសិទ្ធិដីមិនទាន់ចុះបញ្ជី តាមរយៈច្រកចេញចូលតែមួយ**

- ចុះវាស់វែង និងធ្វើរបាយការណ៍ដីមិនទាន់ចុះបញ្ជីបាន ១២៩ ក្បាលដី
- ធ្វើសលាកប័ត្រសម្រង់ជាក់ស្តែង នៃអចលនទ្រព្យមិនទាន់ចុះបញ្ជីបាន ០៨៦ក្បាលដី

**៤. ការងារសំណង់**

- សំណង់ដែលបានចរន្តការបញ្ចប់នៅការិយាល័យភូមិបាលមានចំនួន **៣០៦ច្បាប់**
- សមត្ថកិច្ចក្រុងព្រះសីហនុ មាន ១៤៨ ច្បាប់
- សមត្ថកិច្ចខេត្តព្រះសីហនុ មាន ៨៣ ច្បាប់
- សមត្ថកិច្ចក្រសួង មាន ៧៥ ច្បាប់

**៥. ការចុះស្រង់ស្ថិតិសំណង់ក្នុងក្រុង**

ការដ្ឋានសំណង់ក្នុងភូមិសាស្ត្រក្រុង សរុបចំនួន **៩៩៨ ការដ្ឋាន** ក្នុងនោះការដ្ឋានផ្អាកសកម្មភាពសាងសង់ចំនួន**៣៦៧** ការដ្ឋានកំពុងដំណើរការសាងសង់ចំនួន**៤២២** និងបានសាងសង់រួចចំនួន **២០៩**។

- ការដ្ឋានសំណង់ក្នុងសង្កាត់លេខ១ មានចំនួន **២២០ ការដ្ឋាន**
- ការដ្ឋានសំណង់ក្នុងសង្កាត់លេខ២ មានចំនួន **១០០ ការដ្ឋាន**
- ការដ្ឋានសំណង់ក្នុងសង្កាត់លេខ៣ មានចំនួន **២៤៩ ការដ្ឋាន**
- ការដ្ឋានសំណង់ក្នុងសង្កាត់លេខ៤ មានចំនួន **៤២៩ ការដ្ឋាន**

**៦. ការងារដោះស្រាយវិវាទដីធ្លី**

- ទទួលពាក្យបណ្តឹងចំនួន ២១ ករណី
- ដោះស្រាយបញ្ចប់ចំនួន ២០ ករណី
- កំពុងដោះស្រាយចំនួន ០១ ករណី

## VIII. **វិស័យទេសចរណ៍**

**១/. ទីតាំងទេសចរណ៍**

- តំបន់ឆ្នេរ ( ឆ្នេរជ័យជំនះ ឆ្នេរលំហែកាយ ឆ្នេរឯករាជ្យ ឆ្នេរសុខា ឆ្នេរអូរឈើទាល ឆ្នេរអូរត្រេះ )
- កោះ ( កោះព្រាប កោះដែកគោល កោះពស់ កោះថាស និងកោះត្រេះ )
- រមណីយដ្ឋានទឹកធ្លាក់ក្បាលឆាយ ។

**២/. ទីតាំងសេវាកម្មបម្រើវិស័យទេសចរណ៍ ចំនួន ៨៩៧ទីតាំង ( ផ្អាក ៣៣៤ទីតាំង ) ក្នុងនោះមាន៖**

- សណ្ឋាគារ ចំនួន ២៤៩ ទីតាំង ផ្អាក ១០៦ ទីតាំង
- វីឡា ចំនួន ១២ ទីតាំង ផ្អាក ០៧ ទីតាំង
- បឹងហ្គាឡូ ចំនួន ១១ ទីតាំង ផ្អាក ០៥ ទីតាំង
- បុរី ចំនួន ១៨ ទីតាំង ផ្អាក ០១ ទីតាំង
- ផ្ទះសំណាក់ ចំនួន ១២២ ទីតាំង ផ្អាក ៤០ទីតាំង
- ភោជនីយដ្ឋាន ចំនួន ៦៤ទីតាំង ផ្អាក ៣០ ទីតាំង
- អាហារដ្ឋាន ចំនួន ៦៩ ទីតាំង ផ្អាក ២៨ ទីតាំង
- កាស៊ីណូ ចំនួន ៧០ទីតាំង ផ្អាក ៣៣ ទីតាំង
- ខារ៉ាអូខេ ចំនួន ១៣ទីតាំង ផ្អាក ១២ ទីតាំង
- មណ្ឌលកម្សាន្ត ចំនួន ០៦ទីតាំង ផ្អាក ០៥ ទីតាំង
- មណ្ឌលពាណិជ្ជកម្ម ចំនួន ១៥ទីតាំង ផ្អាក ០២ ទីតាំង
- ស្ប៉ា និងម៉ាស្សា ចំនួន ១១ទីតាំង ផ្អាក ០២ ទីតាំង
- ក្រៅពីនោះមានដេប៉ូ ហាងទំនិញ សេវាកម្ម និងហាងលក់សម្ភារៈប្រើប្រាស់ផ្សេងៗ សរុបចំនួន **២៣៧ទីតាំង ( ផ្អាក ៦៣ទីតាំង )** ។

### ៣/. ភ្ញៀវទេសចរ

- ភ្ញៀវទេសចរទេសចរឆ្នាំ២០២០ សរុបចំនួន ១.០១៨.៩២៣នាក់ ភ្ញៀវទេសចរឆ្នាំ២០១៩ ចំនួន ២.២២៩.៤៨២នាក់ ថយចុះ ៥៤,៣០%។
- ភ្ញៀវទេសចរជាតិ ឆ្នាំ២០២០ សរុបចំនួន ៧៩៣.៦០៧នាក់ ភ្ញៀវទេសចរជាតិឆ្នាំ២០១៩ ចំនួន ១.៣៤៣.៦៩០នាក់ ថយចុះ ៤០,៩៣%។
- ភ្ញៀវទេសចរអន្តរជាតិ ឆ្នាំ២០២០ សរុបចំនួន ២២៥.៣១៦នាក់ ភ្ញៀវទេសចរចំនួន ៨៨៥.៧៩២ នាក់ ថយចុះ ៧៤,៥៦%។

* ក្នុងពិធីបុណ្យឆ្លងឆ្នាំសកលថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងថ្ងៃទី០២ មករា ឆ្នាំ២០២១ រយៈពេល ០៣ថ្ងៃ មានភ្ញៀវដែលបានចូលរួម (ទាំងភ្ញៀវទេសចរ និងភ្ញៀវក្នុងក្រុង) សរុបចំនួន ១១១.៩៩៦នាក់ ក្នុងនោះភ្ញៀវជាតិសរុប ១០៨.៣៣៣នាក់ និងភ្ញៀវបរទេសសរុប ៣.៦៦៣នាក់។ ដោយឡែកភ្ញៀវទេសចរ(សុទ្ធ) សរុប ៩៨.៨៤៤នាក់ កើនឡើង ២,៣៩% ធៀបនឹងឆ្នាំ២០១៩ មានដូចខាងក្រោម៖

- ភ្ញៀវទេសចរជាតិ ៩៥.១៩០នាក់ កើនឡើង ២៦,២០%
- ភ្ញៀវទេសចរបរទេស ៣.៦៦៣នាក់ ថយចុះ៨២,៦៤% ក្នុងនោះ ៖
  - ភ្ញៀវទេសចរតាមព្រលានយន្តហោះអន្តរជាតិក្រុងព្រះសីហនុ ០៣ជើង ចំនួន ១១៥នាក់ (ចិន)
  - ភ្ញៀវទេសចរទៅកម្សាន្តតាមកោះនានា ភ្ញៀវទេសចរសរុប ៤.៦៦៨នាក់ កើនឡើង១៣៤,៦៩% ភ្ញៀវទេសចរជាតិ ៣.៨១២នាក់ កើនឡើង៤០៨,២៦% ភ្ញៀវទេសចរបរទេស ៨៥៦នាក់ ថយចុះ៣០,៩១%។
  - ភ្ញៀវទៅកម្សាន្តតាមបណ្ដាឆ្នេរ និង រមណីយដ្ឋាននានារួមមានៈ ភ្ញៀវសរុប៧៩.២៧២នាក់ កើនឡើង៦០,៣២% ភ្ញៀវជាតិ ៧៧.០៨៧នាក់ កើនឡើង៦០,៥០% និងភ្ញៀវបរទេស ២.១៨៥នាក់ កើនឡើង៥៤,១៩%។

## IX- ការងារអនាម័យ-បរិស្ថាន

### ១. ការងារប្រមូល បោសសម្អាត និងដឹកជញ្ជូនសំរាម (KSWM)

រដ្ឋបាលក្រុងព្រះសីហនុ បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ខេ-អេស-ដាប់ប៊ែលយូ-អិម ឯ.ក (KSWM) ក្នុងការវិនិយោគលើអាជីវកម្មផ្តល់សេវាប្រមូល បោសសម្អាត និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជន នៅក្នុងក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៩ ដែលមានរយៈពេល ១០ឆ្នាំ ក្នុងកិច្ចសន្យាមួយលើក ដោយបច្ចុប្បន្នក្រុមហ៊ុនប្រមូល សម្អាត និងដឹកជញ្ជូនសំរាម (KSWM) មានដូចខាងក្រោម ៖

- បុគ្គលិករបស់ក្រុមហ៊ុនសរុបចំនួន ២០៧នាក់ ក្នុងនោះ ផ្នែកប្រតិបត្តិការ និងដឹកជញ្ជូន ១២៥នាក់ យានដ្ឋាន ផ្នែកទីលាន ៣៥នាក់ ផ្នែកសេវាអតិថិជន ១៦នាក់ និងបុគ្គលិសម្អាតអនាម័យ ១០នាក់។
- រថយន្ត និងគ្រឿងចក្រប្រតិបត្តិការ សរុប ១០២គ្រឿង
- រថយន្តបោសថ្នល់សរុបចំនួន ០៣គ្រឿង (ទើបបន្ថែមថ្មី ១គ្រឿង)
- ទ្រុងកុងតឺន័រ ១០៩ទ្រុង ក្នុងនោះក្រសួងបរិស្ថានផ្តល់មក ៣០ទ្រុង
- សម្ភារៈប្រើប្រាស់ផ្សេងៗ ៤៩០។

- ធុងសំរាមដាក់តាមទីសាធារណៈនានាក្នុងក្រុង ចំនួន ៦៥៣ធុង មាន ១៨ទីតាំង ក្នុងនោះ ៤០០ធុង ប្រគល់ជូនសាលាក្រុងព្រះសីហនុ។
- ក្នុងឆ្នាំ២០២០នេះ ក្រុមហ៊ុនប្រមូលសំរាមសរុបចំនួន **១២៣.៣១០តោន** ដោយបរិមាណសំរាម បច្ចុប្បន្ននៅក្រុងព្រះសីហនុ មានចំនួនប្រមាណ **៣៨០-៤០០តោន** ប៉ុណ្ណោះក្នុង១ថ្ងៃ បើប្រៀបធៀប នឹងឆ្នាំ២០១៩ ក្រុមហ៊ុនប្រមូលសំរាមបានប្រមាណ **៥៧៦.០០០តោន** ដោយបរិមាណសំរាម ចន្លោះ ពី ១.៥០០តោន ទៅ១.៨០០តោន ក្នុងមួយថ្ងៃ។
- ប្រជាពលរដ្ឋភ្ជាប់សេវាសំរាម សរុបចំនួន **៥.៩៣៩ទីតាំង** ក្នុងនោះ៖
  - សង្កាត់លេខ១ ចំនួន ២.១១៤ ទីតាំង
  - សង្កាត់លេខ២ ចំនួន ៦៩០ ទីតាំង
  - សង្កាត់លេខ៣ ចំនួន ៨១៣ ទីតាំង
  - សង្កាត់លេខ៤ ចំនួន ២.៣២២ ទីតាំង
- ទីលានចាក់សំរាម មានចំនួន ១កន្លែង ទំហំ ៦៥ហិកតា (បច្ចុប្បន្នប្រើប្រាស់ជាង ២ហិកតា) ស្ថិតនៅ ភូមិអូរតាសេក ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ មានចម្ងាយ ៣៦គីឡូម៉ែត្រ (ស្មើនឹង ៧២គីឡូម៉ែត្រផ្លូវទៅមក) ពីក្រុងព្រះសីហនុ។

## ២. ការងារប្រមូល និងដឹកជញ្ជូនសំណល់សំណង់

នៅក្នុងក្រុងព្រះសីហនុ មានក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំណល់សំណង់ចំនួន ០៣ក្រុមហ៊ុន គឺ ក្រុមហ៊ុន**សេង ទិត្យ** ក្រុមហ៊ុន **ឆាវ ឆាវ** និងក្រុមហ៊ុន **មិត្ត ចេង** ដែលបានទទួលសិទ្ធិពីរដ្ឋបាលខេត្ត ព្រះសីហនុ ក្នុងការប្រមូល និងដឹកជញ្ជូនកាកសំណង់សំណង់ក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ ដែល ក្នុងឆ្នាំ២០២០នេះ ការប្រមូល និងដឹកជញ្ជូនសំណល់សំណង់ក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ សរុប បានចំនួន **២៨.៧៣៧ តោន** ដោយក្នុងនោះក្រុមហ៊ុន ឆាវឆាវ ពុំមានសកម្មភាពប្រមូល និងដឹកកាក សំណល់សំណង់នោះទេ។

### ក/. ក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំណល់សំណង់ សេង ទិត្យ

- លិខិត០៩៦/១៩ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តព្រះសីហនុ បានទទួល សិទ្ធិធ្វើអាជីវកម្មប្រមូល និងដឹកជញ្ជូនសំណល់សំណង់ទូទាំងក្រុងព្រះសីហនុ។
- មានបុគ្គលិកសរុបចំនួន **២៨នាក់** ។
- គ្រឿងចក្របម្រើឱ្យការប្រមូល និងដឹកជញ្ជូនសំណល់សំណង់សរុបចំនួន ២០គ្រឿង ក្នុង នោះរួមមានៈ ឡានដឹកចំណុះ ១២តោនចំនួន ០៤គ្រឿង ឡានដឹកចំណុះ ៥តោនចំនួន ០៨ គ្រឿង អេស្កាវ៉ាទ័រ ចំនួន ០២គ្រឿង អាប៊ុល ០១គ្រឿង និងសាសី ០៥គ្រឿង ក្នុងនោះមាន សាសីចំនួន ០២គ្រឿង ដែល**ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តព្រះសីហនុ ផ្តល់ឱ្យប្រើប្រាស់ក្នុងការពន្លឿនកិច្ចការងារ ប្រមូលកាកសំណល់សំណង់ក្នុងក្រុង។
- ដឹកកាកសំណល់សំណង់ចេញពីក្រុងចំនួន១២៥-១៥០ តោន/ថ្ងៃ ។
- ការប្រមូល និងដឹកជញ្ជូនសំណល់សំណង់ទូទាំងក្រុង សរុបចំនួន ២៤.៧៣៧ តោន ។

២/. ក្រុមហ៊ុនប្រមូល និងដឹកជញ្ជូនសំណល់សំណង់ មិត្តចេង

- លិខិតលេខ០៥២/២០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២០ របស់រដ្ឋបាលខេត្តព្រះសីហនុ ធ្វើអាជីវកម្មប្រមូល និងដឹកជញ្ជូនសំណល់សំណង់ក្នុងភូមិសាស្ត្រសង្កាត់លេខ២ និងសង្កាត់លេខ៤។
- មានបុគ្គលិកសរុបចំនួន ១០នាក់ ។
- គ្រឿងចក្របម្រើឱ្យការប្រមូល និងដឹកជញ្ជូនសំណល់សំណង់សរុបចំនួន ០៨គ្រឿង ក្នុងនោះមានឡានដឹកចំណុះ ០៥តោន ចំនួន ០៥គ្រឿង សាសីចំនួន ០២គ្រឿង និងអេស្កាវ៉ាទ័រ ចំនួន ០២គ្រឿង។
- ដឹកកាកសំណល់សំណង់ចេញពីក្រុងចំនួន ៣១-៤០តោន ក្នុង/ថ្ងៃ។
- ការប្រមូល និងដឹកជញ្ជូនសំណល់សំណង់ទូទាំងក្រុង សរុបចំនួន ៤.០០០ តោន ។

## ៣. ការសម្អាតអនាម័យតាមដងផ្លូវសាធារណៈ

- ការសម្អាតតាមដងផ្លូវសាធារណៈដោយប្រើប្រាស់រថយន្តសម្អាតថ្នល់ មានសរុបចំនួន ០៥គ្រឿង ក្នុងនោះរថយន្តសម្អាតថ្នល់របស់សាលាក្រុងព្រះសីហនុ ចំនួន ០២គ្រឿង និងរថយន្តសម្អាតថ្នល់របស់ក្រុមហ៊ុន KSWM ចំនួន ០៣គ្រឿង។
- ការសម្អាតតាមដងផ្លូវសាធារណៈ ដោយប្រើប្រាស់កម្លាំងបុគ្គលិកអនាម័យសរុបចំនួន ៦០នាក់ ក្នុងនោះ បុគ្គលិកអនាម័យក្រុងព្រះសីហនុចំនួន **៥០នាក់** ទទួលប្រាក់ឧបត្ថម្ភពីកញ្ចប់សេវាអនាម័យបរិស្ថានរបស់ក្រសួងបរិស្ថាន និងបុគ្គលិកអនាម័យរបស់ក្រុមហ៊ុនKSWM ចំនួន ១០នាក់។

## ៤. ការច្រកបាវខ្សាច់ទប់ដើមឈើនៅតំបន់ឆ្នេរ

ដោយមានការចង្អុលបង្ហាញពី**ឯកឧត្តម គួច ចំរើន** អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ រដ្ឋបាលក្រុងព្រះសីហនុ ដោយមានការចូលរួមសហការពីមន្ទីរ-អង្គភាពពាក់ព័ន្ធ និងក្រុមហ៊ុនដឹកជញ្ជូនសំរាម(KSWM) ក្រុមហ៊ុនដឹកកាកសំណល់សំណង់ ប្រើប្រាស់កម្លាំងសរុប ក្នុងមួយលើកៗ ចំនួន **១៣០នាក់** ឡានសាសីចំនួន ០២គ្រឿង បាវក្រចៅចំនួន ១២.០០០បាវ ប៉ែល៣៥ ខ្សែចងបាវ ២៥ដុំ និងម្ជុលដេរបាវ៣០ ដើម្បីច្រកខ្សាច់ដាក់បាវទប់គល់ឈើតាមបណ្តោយឆ្នេរ ការពារកុំឱ្យបាក់រលំដោយទឹករលកសមុទ្រ និងខ្យល់បោកបក់ សរុបបានចំនួន **២៣៧ដើម** ស្មើនឹង **០៧លើក** មានដូចខាងក្រោម ៖

- លើកទី១ នៅឆ្នេរអូរឈើទាល១-២ ចំនួន ១៣ដើម
- លើកទី២ នៅអូរឈើទាល-២ ចំនួន ៤៤ដើម
- លើកទី៣ នៅអូរឈើទាល-២ និងអូរត្រេះ-១ ចំនួន ១៩ដើម
- លើកទី៤ នៅអូរឈើទាល-២ និងអូរត្រេះ-១ ចំនួន ៤៣ដើម
- លើកទី៥ នៅអូរត្រេះ-១ ចំនួន ១៣ដើម
- លើកទី៦ នៅអូរត្រេះ-២ ចំនួន ៣២ដើម
- លើកទី៧ នៅអូរត្រេះ-២ ចំនួន ៤៧ដើម

X- **ការខារប្រយុទ្ធប្រឆាំងជម្ងឺកូវីដ-១៩** ( Covid-19 )

**កម្ពុជា** ក្រោមការដឹកនាំប្រកបដោយបញ្ញាញាណឈ្លៀសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានមានចំណាត់ការឆ្លើយតបចំពោះវិធានការដោះស្រាយ ការពារ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងជម្ងឺកូវីដ-១៩(Covid-19) ក្នុងក្របខណ្ឌទូទាំងប្រទេស បានម៉ត់ចត់ ច្បាស់លាស់ គ្រប់ជ្រុងជ្រោយ និងទាន់ពេលវេលា ជាពិសេសការសម្រេចដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោ** ក្នុងការអនុញ្ញាតឱ្យនាវាទេសចរណ៍ខ្នាតយក្ស(WASTERDAM) របស់សហរដ្ឋអាមេរិក ចូលចតនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ កាលពីព្រឹកថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ដែលមានផ្ទុកអ្នកដំណើរប្រមាណជាង ១.៤៥៥នាក់ មកពី ៤១ជនជាតិ និងមានបុគ្គលិកបម្រើការងារក្នុងនោះចំនួន ៨០២នាក់ និងដំណើរសួរសុខទុក្ខនៅទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន ដែលធ្វើឱ្យសាធារណៈមតិជាតិ -អន្តរជាតិ មានការកោតសសើរយ៉ាងខ្លាំង ចំពោះវីរភាពដ៏អង់អាចក្លាហានរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** នៃព្រះរាជាណាចក្រកម្ពុជា ។

អនុវត្តតាមសារាចរណែនាំ បទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា សេចក្តីណែនាំ និងសេចក្តីជូនដំណឹងរបស់ក្រសួងសុខាភិបាល ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលខេត្តព្រះសីហនុ ហើយរដ្ឋបាលក្រុង បានដាក់ចេញនូវវិធានការបង្ការ ការពារ ទប់ស្កាត់ គ្រប់គ្រង និងប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃវីរុសកូវីដ-១៩ ឆ្លើយតបបានទាន់ពេលវេលានៅតាមបណ្តាមូលដ្ឋានភូមិ-សង្កាត់ សាលារៀន វត្តអារាម មូលដ្ឋានអាជីវកម្ម រោងចក្រសហគ្រាស ក្រុមហ៊ុន សណ្ឋាគារ ភោជនីយដ្ឋាន និងតាមកន្លែងកម្សាន្តសប្បាយនានាក្នុងក្រុង និងមានការជួយឧបត្ថម្ភជាថវិកា គ្រឿងឧបភោគ បរិភោគ និងសម្ភារវេជ្ជសាស្ត្រជាបន្តបន្ទាប់ពីសំណាក់សប្បុរសជនជាតិ និងអន្តរជាតិ។

**១. ការចុះផ្សព្វផ្សាយ**

បន្ទាប់ពីទទួលបានសេចក្តីណែនាំលេខ០០៣ សណន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃ ស្តីពីការផ្សព្វផ្សាយអំពីវិធានការបង្ការ ទប់ស្កាត់ ការរាតត្បាតនៃជម្ងឺកូវីដ-១៩ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងដោយបានការណែនាំពីឯកឧត្តមអភិបាលខេត្ត រដ្ឋបាលក្រុង បានបើកកិច្ចប្រជុំផ្សព្វផ្សាយអំពីវិធានការបង្ការ ទប់ស្កាត់ ការរាតត្បាតនៃជម្ងឺកូវីដ-១៩ សម្រាប់ក្រុងព្រះសីហនុ និងបានបង្កើតក្រុមការងារដើម្បីធ្វើការចុះផ្សព្វផ្សាយពីវិធានការ ការពារ ទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងជម្ងឺកូវីដ-១៩ ជារៀងរាល់ថ្ងៃ ចាប់ពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន មានដូចខាងក្រោម៖

- ចុះផ្សព្វផ្សាយសរុបចំនួន **៣.០៨០លើក**
- ប្រើប្រាស់រថយន្តសរុបចំនួន ៧គ្រឿង (ម៉ូតូចំនួន **៤៣គ្រឿង** ធុងបាស់ **២៣គ្រឿង** និងអ្នកចូលរួមចុះផ្សព្វផ្សាយចំនួន **២២០នាក់** និងបានបិទផ្ទាំងផ្សព្វផ្សាយ (Poster) ស្តីពីកាត់បន្ថយហានិភ័យពីការឆ្លងជម្ងឺកូវីដ-១៩ ចំនួន **២.៧៣៥សន្លឹក** ) រួមមានដូចខាងក្រោម៖
  - សាលាក្រុង ផ្សព្វផ្សាយចំនួន **២៦៣លើក** ប្រើប្រាស់រថយន្តក្រុង ២គ្រឿង ធុងបាស់ ៥គ្រឿង អ្នកផ្សព្វផ្សាយ ៧នាក់ និងបានប្រើប្រាស់ផ្ទាំងPoster ចំនួន ២.២៥០សន្លឹក។
  - កងរាជអាវុធហត្ថ ផ្សព្វផ្សាយចំនួន ៩៨លើក ប្រើប្រាស់រថយន្ត ១គ្រឿង ធុងបាស់ ១គ្រឿង និងកម្លាំងចុះផ្សព្វផ្សាយ ៤នាក់ និងបានប្រើប្រាស់ផ្ទាំងPoster ចំនួន ៥០សន្លឹក។
  - សង្កាត់លេខ១ ផ្សព្វផ្សាយចំនួន ៦១៤លើក ប្រើប្រាស់រថយន្ត ៤គ្រឿង ម៉ូតូ ១៣គ្រឿង ធុងបាស់ ៤គ្រឿង និងអ្នកចុះផ្សព្វផ្សាយ ២៧នាក់ និងបានប្រើប្រាស់ផ្ទាំងPoster ចំនួន ១១៥សន្លឹក។

- សង្កាត់លេខ២ ផ្សព្វផ្សាយចំនួន ៣៩៥លើក ប្រើប្រាស់ម៉ូតូ ១៣គ្រឿង ធុងបាស់ ៣គ្រឿង និងអ្នកចុះផ្សព្វផ្សាយ ១៧នាក់ និងបានប្រើប្រាស់ផ្ទាំងPoster ចំនួន ១០០សន្លឹក។
- សង្កាត់លេខ៣ ផ្សព្វផ្សាយចំនួន ៤៥០លើក ប្រើប្រាស់ម៉ូតូ ១១គ្រឿង ធុងបាស់ ៣គ្រឿង និងអ្នកចុះផ្សព្វផ្សាយ ១៣នាក់ និងបានប្រើប្រាស់ផ្ទាំងPoster ចំនួន ១០០សន្លឹក។
- សង្កាត់លេខ៤ ផ្សព្វផ្សាយចំនួន ៩៤០លើក ប្រើប្រាស់រថយន្ត ១គ្រឿង ម៉ូតូ ៦គ្រឿង ធុងបាស់ ៧គ្រឿង និងអ្នកចុះផ្សព្វផ្សាយ ១៩នាក់ និងបានប្រើប្រាស់ផ្ទាំងPoster ចំនួន ១១៥សន្លឹក។
- ផ្សារលើ ផ្សព្វផ្សាយចំនួន ៣២០លើក បានរៀបចំធុងបាស់ ២គ្រឿង ទឹកអាកុល និងអ្នកចុះផ្សព្វផ្សាយ ៩នាក់ និងបានប្រើប្រាស់ផ្ទាំងPoster ចំនួន ៥០សន្លឹក។

## ២.ការងារអប់រំក្នុងអំឡុងពេលជម្ងឺកូវីដ-១៩ (Covid-19)

* នៅក្នុងក្រុងព្រះសីហនុ មានគ្រឹះស្ថានសិក្សារដ្ឋចំនួន ១៩សាលា ដែលមានសិស្សានុសិស្សសរុបចំនួន ១៥.២៣៣ នាក់ ស្រីចំនួន ៧.៤៩៤នាក់ ក្នុងនោះសិស្សថ្នាក់ទី៩ មានចំនួន ៨០០នាក់ (ស្រី ៤០៥នាក់) សិស្សថ្នាក់ទី១២ មានចំនួន ៥៨២នាក់ (ស្រីចំនួន ២៩៨នាក់) និងបុគ្គលិកអប់រំចំនួន ៧៣៨នាក់ (ស្រីចំនួន ៣៥៤នាក់)។

* ក្រោយពីមានបញ្ហារីករាលដាលនៃវីរុសកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានណែនាំឱ្យសិស្ស និងគ្រូបង្រៀនទាំងអស់ ធ្វើការបង្រៀន-រៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក។

* នៅដំណាក់កាលទី១ ចាប់ពីអំឡុងខែមេសា ដល់ខែកញ្ញា ឆ្នាំ២០២០ មានសិស្សរៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិកសរុបចំនួន ១១.០៦០ នាក់ (ស្រី ៥.៨៣៥នាក់) ក្នុងចំណោមសិស្សសរុប **១៥.៥៣៦** នាក់ ( ស្រី ៧.៦១១នាក់ ) ក្នុងនោះរួមមាន៖

- សិស្សបានរៀនតាមសៀវភៅសិក្សាគោល (សិស្សក្រីក្រ) សរុបចំនួន ១.៥៣៩ នាក់ ស្រី៦៩០ នាក់
- សិស្សបានរៀនតាមការសិក្សាពីចម្ងាយតាមរយៈទូរទស្សន៍រដ្ឋ សរុបចំនួន ៣.០៧១ ស្រី ១.៦៧៨នាក់
- សិស្សបានរៀនតាមប្រព័ន្ធអេឡិចត្រូនិក សរុបចំនួន ៦.៤៥០ នាក់ ស្រី ៣.៤៦៧នាក់

* នៅដំណាក់កាលទី២ ចាប់ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានបើកការចូលរៀនឡើងតាមគ្រឹះស្ថានសិក្សាឡើងវិញ ដោយអនុវត្តតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងនោះក៏នៅបន្តការបង្រៀន និងរៀនពីចម្ងាយ និងរៀនតាមប្រព័ន្ធអេឡិច-ត្រូនិចផងដែរ។

* ការិយាល័យអប់រំ យុវជន និងកីឡាក្រុងព្រះសីហនុ បានចុះផ្សព្វផ្សាយ និងណែនាំដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាក្នុងក្រុងព្រះសីហនុទាំងអស់ ឱ្យអនុវត្តវិធានការគោលការណ៍ប្រតិបត្តិស្តង់ដារSOP (Standard Operation Program) ជាប្រចាំតាមគ្រឹះស្ថានសិក្សាក្នុងក្រុងព្រះសីហនុ ដើម្បីបង្ការ ការពារ ទប់ស្កាត់ការឆ្លងរីករាលដាលនៃជម្ងឺកូវីដ-១៩។

* ពាក់ព័ន្ធនឹងការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា២០១៩-២០២០ ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់ឱ្យ **"ជាប់ជាស្ថាពរ"** ចំពោះបេក្ខជនទាំងអស់ដែលបានចុះឈ្មោះប្រឡង និងគ្មានការកំណត់និទ្ទេស ដោយអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

## ៣. ការតាមដានចំនួនពលករចំណាកស្រុក

ក្នុងឆមាសទី១ ក្រុមការងាររដ្ឋបាលក្រុង បានចុះពិនិត្យ និងតាមដាននៅតាមបណ្តាសង្កាត់ទាំង៤ ឃើញថា កម្មករចំណាកស្រុកពីប្រទេសថៃចំនួន **១០នាក់** ក្នុងនោះស្រី **៥នាក់** ដែលរស់នៅក្នុងសង្កាត់លេខ១ បានដាក់នៅដាច់ដោយឡែកពីក្រុមគ្រួសាររយៈពេល ១៤ថ្ងៃ ក្រោយពីបានធ្វើចត្តាឡីស័ករួច ហើយគាត់ទាំង ១០នាក់ គឺមានសុខភាពល្អធម្មតា។

## ៤. ការធ្វើចត្តាឡីស័ក

### ក/. ការធ្វើចត្តាឡីស័កក្រោយពេលបុណ្យចូលឆ្នាំខ្មែរ

ក្នុងឆមាសទី១ រដ្ឋបាលក្រុងព្រះសីហនុ បានបង្កើតក្រុមការងារគ្រប់គ្រងបុគ្គលិក កម្មករ-កម្មការិនីដែលទើបវិលត្រឡប់មកពីស្រុកកំណើតក្នុងឱកាសពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ដែលបានកំណត់យកទីតាំងសម្រាប់ធ្វើចត្តាឡីស័ក នៅសាលាបឋមសិក្សា-អនុវិទ្យាល័យតេជោសែនកម្មករ ក្នុងនោះមានកម្មករ-កម្មការិនីចំនួន **៩៩នាក់** ក្នុងនោះស្រី **៤៩នាក់** ពិនិត្យសុខភាពឃើញថាល្អធម្មតា ហើយបានអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញ ប៉ុន្តែពួកគាត់ត្រូវនៅដាច់ដោយឡែកពីគ្រួសាររយៈពេល ១៤ថ្ងៃ ដើម្បីតាមដានបន្ថែម។

### ខ/. ការធ្វើចត្តាឡីស័កភ្ញៀវបរទេសតាមច្រកព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុ

នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០ រាជរដ្ឋាភិបាល បានដាក់គោលការណ៍អនុវត្តចត្តាឡីស័កអ្នកធ្វើដំណើរបរទេសតាមច្រកព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុ ហើយខេត្តព្រះសីហនុ បានចាប់អនុវត្តពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០ ដោយក្នុងនោះរដ្ឋបាលខេត្ត បានរៀបចំមណ្ឌលសម្រាប់ធ្វើចត្តាឡីស័កភ្ញៀវបរទេសតាមច្រកព្រលានយន្តហោះអន្តរជាតិខេត្តព្រះសីហនុ ចំនួន ០៥ទីតាំង ស្មើនឹង ១.៣៧៤បន្ទប់ មានដូចខាងក្រោម ៖

- សណ្ឋាគារឃ្វីនកូ ចំនួន ១១៦ បន្ទប់
- សណ្ឋាគារហ្គោលដិនស៊ី ចំនួន ១៥៧ បន្ទប់
- សណ្ឋាគារសុខា ចំនួន ៥៣២ បន្ទប់
- សណ្ឋាគារវ៉ាយជ្រាហ្គន ចំនួន ២៤៧ បន្ទប់
- សណ្ឋាគារប្លូបេ ចំនួន ៣២២ បន្ទប់។

* ភ្ញៀវបរទេសដែលបានធ្វើចត្តាឡីស័កសរុបចំនួន **១៦.៩៩៩នាក់** ស្រី ៣.៤០៦នាក់ ( ស្មើនឹង ១៩៣ជើងហោះហើរ ) ក្នុងនោះមានជនជាតិចិន ១៦.៧៨០នាក់ (ក្មេង ១៤នាក់) ជនជាតិខ្មែរ ៣២នាក់ សាំហ្គាពួរ ២នាក់ វៀតណាម ៦៧នាក់ អូស្ត្រាលី ១នាក់ ភូមា ១នាក់ អាមេរិក ២នាក់ ឥណ្ឌូនេស៊ី ១២នាក់ អង់គ្លេស ១នាក់ និងថៃ ១០០នាក់ ( ទិន្នន័យចាប់ពីថ្ងៃទី២៣ ខែឧសភា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ )។

## XI- ទិសដៅ

- បន្តអនុវត្តស្មារតីផែនការណែនាំលេខ ០២០៨.ក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ របស់ក្រសួងមហាផ្ទៃស្តីពីការចាត់តាំងអនុវត្តគោលនយោបាយភូមិ-ឃុំ/សង្កាត់ មានសុវត្ថិភាពទាំង ៩ចំណុច ដើម្បីពង្រឹងសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាពសង្គមបានកាន់តែល្អប្រសើរបម្រើដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមក្នុងក្រុង ក៏ដូចជាការរស់នៅរបស់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរជាតិ-អន្តរជាតិ ព្រមទាំងអ្នកវិនិយោគ ដែលកំពុងរស់នៅ និងវិនិយោគនៅក្រុងព្រះសីហនុ។

- បន្តលើកកម្ពស់គោលការណ៍អភិបាលកិច្ចល្អ ការកែទម្រង់ប្រព័ន្ធរដ្ឋបាល ដោយពង្រីកវិសាលភាពសេវាកម្មដែលផ្តល់ដោយរដ្ឋបាលក្រុង ឱ្យបានទូលំទូលាយតាមរយៈការប្រមូលផ្តុំសេវាកម្មទាំងអស់ ក្នុងក្របខណ្ឌសមត្ថកិច្ចរបស់រដ្ឋបាលក្រុង ដែលត្រូវផ្តល់ជូនដល់ប្រជាពលរដ្ឋ។
- បន្តកែលំអរការផ្តល់សេវាសាធារណៈ កាត់បន្ថយអំពើពុករលួយ និងបង្កើនការជឿទុកចិត្តពីប្រជាពលរដ្ឋ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការផ្តល់មតិយោបល់ និងការរិះគន់ស្ថាបនា ដើម្បីកែលំអរការអនុវត្តប្រព័ន្ធរដ្ឋបាល។
- បន្តបង្វិតរដ្ឋបាលឱ្យនៅកៀកជិតនឹងប្រជាពលរដ្ឋ បង្កភាពងាយស្រួលក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ឱ្យបានឆាប់រហ័ស ប្រកបដោយប្រសិទ្ធភាព គុណភាព តម្លាភាព ឆ្លើយតបទាន់ពេលវេលាទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។
- បន្តខិតខំរៀបចំសណ្តាប់ធ្នាប់ របៀបរៀបរយ នៅតាមបណ្តាផ្លូវ បណ្តោយឆ្នេរ និងទីសាធារណៈក្នុងភូមិសាស្ត្រក្រុងព្រះសីហនុ ដើម្បីរក្សាបាននូវបរិស្ថាន និងសោភ័ណភាពទីក្រុង។
- បន្តខិតខំអភិវឌ្ឍនៅមូលដ្ឋាន ដើម្បីការរស់នៅសុខសាន្ត និងបង្កើនជីវភាពរបស់ប្រជាពលរដ្ឋ។
- បន្តខិតខំទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីរដ្ឋ និងដីសាធារណៈពីសំណាក់ជនឱកាសនិយម។
- បន្តប្រជុំប្រចាំខែ និងជំរុញដល់ក្រុមហ៊ុនផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាម ( KSWM ) ក្នុងការផ្តល់សេវាប្រមូល និងដឹកជញ្ជូនសំរាមឱ្យបានលឿន និងភ្ជាប់សេវាសំរាមឱ្យបានគ្រប់ទីតាំងបង្កើតសំរាមនៅទូទាំងក្រុងព្រះសីហនុ។
- បន្តសហការជាមួយក្រុមការងារក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រុមការងារគ្រប់គ្រងប្រព័ន្ធលូអូរ-ប្រឡាយថ្នាក់ខេត្ត ដើម្បីពន្លឿនក្នុងការកាយ-ស្តារ អូរប្រឡាយ ដែលនៅសល់ប្រមាណ ២៩% ឱ្យហើយតាមផែនការ។
- បន្តគាំទ្រ និងចាំសហការជានិច្ចជាមួយក្រុមហ៊ុនទាំង៨ ដែលស្ថាបនាផ្លូវទាំង ៣១ខ្សែ និងក្រុមហ៊ុនដែលទទួលស្ថាបនាផ្លូវទាំង ១១ខ្សែ នៅក្នុងក្រុងព្រះសីហនុ។
- បន្តខិតខំបើកផ្លូវតាមប្លង់ជាលក្ខណៈប្រព័ន្ធជូនប្រជាពលរដ្ឋ ដើម្បីមានភាពងាយស្រួលក្នុងការធ្វើចរាចរ។
- បន្តផ្សព្វផ្សាយពីវិធានការ ការពារ ទប់ស្កាត់ គ្រប់គ្រង និងប្រយុទ្ធប្រឆាំងការឆ្លងរីករាលដាលនៃវីរុសកូវីដ-១៩ ឆ្លើយតបបានទាន់ពេលវេលានៅតាមបណ្តាមូលដ្ឋានភូមិ-សង្កាត់ សាលារៀន វត្តអារាម មូលដ្ឋានអាជីវកម្ម រោងចក្រសហគ្រាស ក្រុមហ៊ុន សណ្ឋាគារ ភោជនីយដ្ឋាន និងតាមកន្លែងកម្សាន្តសប្បាយនានាទូទាំងក្រុងព្រះសីហនុ។
- បន្តអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងមតិណែនាំរបស់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ។

ជាទីបញ្ចប់ខ្ញុំបាទ សូមគោរពជូនពរ **ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់** សូមសុខភាពល្អ អាយុវែង សុភមង្គលក្នុងក្រុមគ្រួសារ និងទទួលបានជោគជ័យក្នុងការងារ ៕

**សូមអរគុណ**!